**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥០)

ភាគីដាក់ឯកសារ: ក្រុមការពារក្តីរបស់អ្នកស្រី អ៊ឹម ចែម

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៧

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 12-June-2018, 09:13
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ សាធារណៈ/Public

ប្រភេទចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងសារណារបស់ ស.ម.ត.ជ ស្តីពី ជំហរ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា (D308/3/1/9)**

---

**ដាក់ដោយ៖**

**សហមេធាវី**

ប៊ិត ស៊ាងលីម

Wayne JORDASH, QC

**ផ្ញើជូន៖**

**ចៅក្រមអង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម BAIK Kang Jin

ចៅក្រម ន័យ ថុល

ចៅក្រម Oivier BEAUVALLET

ចៅក្រម ហួត វុទ្ធី

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ទាំងអស់ក្នុងសំណុំរឿង ០០៤/១**

## I. សេចក្ដីផ្ដើម

១. អ្នកស្រី អ៊ឹម ចែម តាមរយៈសហមេធាវីរបស់អ្នកស្រី ("ក្រុមការពារក្ដី") តទៅនេះ សូមដាក់ជូនចម្លើយតបទៅនឹង*សារណារបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អំពីជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា* ("សារណារបស់ ស.ម.ត.ដ")[1] ។ នៅក្នុងសារណា ស.ម.ត.ដ បានជំទាស់នឹងការរកឃើញរបស់ ស.ច.ស ដែលបានលើកឡើងថា "អានុភាពមួយក្នុងចំណោមអានុភាពនានានៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក គឺ 'មិនរាប់បញ្ចូលយុត្តាធិការបុគ្គល ឬយុត្តាធិការបទល្មើសរបស់តុលាការកម្ពុជាធម្មតា ទៅលើព្រឹត្តិការណ៍នានាដែលស្ថិតនៅក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ឡើយ'"[2] ។ ស.ម.ត.ដ យល់ថា ដីកាដំណោះស្រាយ "អះអាងថានឹងដកចេញតាមផ្លូវច្បាប់នូវយុត្តាធិការរបស់តុលាការកម្ពុជាធម្មតា ដែលវិនិច្ឆ័យលើឧក្រិដ្ឋកម្ម*ណាមួយ*ក្នុងសម័យខ្មែរក្រហម រួមទាំងឧក្រិដ្ឋកម្មទាំងឡាយណាដែលស្ថិតនៅក្រៅយុត្តាធិការដែលមានកម្រិតរបស់ អ.វ.ត.ក ផង"[3] ហើយថា ផ្ទុយពីការរកឃើញរបស់ ស.ច.ស តុលាការសាមញ្ញរបស់កម្ពុជាមានយុត្តាធិការលើឧក្រិដ្ឋកម្មនានា ដែលមិនស្ថិតនៅក្នុងវិសាលភាពនៃ អ.វ.ត.ក[4] ។ ស.ម.ត.ដ បានស្នើ អ.ប.ជ ឱ្យ i) កែតម្រូវការរកឃើញក្នុងដីកាដំណោះស្រាយទាក់ទងនឹងបញ្ហាយុត្តាធិការតុលាការសាមញ្ញរបស់កម្ពុជា[5] និង ii) ប្រកាសថា កម្រិតដែល

---

[1] សារណារបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អំពីជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ធ្វើនៅថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៧, ឯកសារ **D308/3/1/9** ("សារណារបស់ ស.ម.ត.ដ") ។ សំណៅបកប្រែជាភាសាខ្មែរនៃសារណានេះ ត្រូវបានដាក់នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៧ ដូច្នេះ ថិរវេលាសម្រាប់ក្រុមការពារក្ដីត្រូវដាក់ការឆ្លើយតប គឺចាប់ផ្ដើមពីរយៈពេល១០ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានការជូនដំណឹងនៃការដាក់សំណៅបកប្រែឯកសារនេះ ។ *សូមមើល*, សារអេឡិចត្រូនិកពីមន្ត្រីទទួលបន្ទុកផ្នែកកិច្ចការសំណុំរឿង ផ្ញើជូនទៅភាគីនានាក្នុងសំណុំរឿង០០៤/១ ក្រោមចំណងជើងថា៖ "សារណារបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអំពីជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា" ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៧ (**ភ្ជាប់ជាឯកសារសំអាងលេខ ១**) ។

[2] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ៣ *ដកស្រង់* ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ២៣ ។

[3] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ៣ (សេចក្ដីសង្កត់ធ្ងន់ត្រង់អក្សរទ្រេតនៃសារណាដើម) ។

[4] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ៨ ។ *សូមមើលផងដែរ*, សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ៩-៣១ ។

[5] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ៣ និងកថាខណ្ឌ ៣២ ។

តុលាការសាមញ្ញរបស់កម្ពុជាមានសមត្ថកិច្ចដោះស្រាយលើឧក្រិដ្ឋកម្មពីសម័យខ្មែរក្រហម គឺជាបញ្ហាមួយដែលត្រូវប្រគល់ឱ្យតុលាការជាតិទាំងនោះ សម្រេចដោយខ្លួនឯង[6] ។

២. នៅក្នុងចម្លើយតបនេះ ក្រុមការពារក្ដីជាបឋមសូមបង្ហាញឱ្យឃើញថា អ.ប.ជ មិនមែនជាវេទិកាសមស្របសម្រាប់ស្ដាប់នូវអំណះអំណាងទាំងឡាយណា ដើម្បីទទួលបានការសម្រេចស្ថាពរចំពោះបញ្ហាយុត្តាធិការតុលាការសាមញ្ញរបស់កម្ពុជា លើឧក្រិដ្ឋកម្មដែលកើតមានក្នុងសម័យខ្មែរក្រហមទេ ។ ដូចត្រូវលើកយកមកពិភាក្សាខាងក្រោម កម្មវត្ថុ និងគោលបំណងរបស់ ស.ច.ស នៅក្នុងការរកឃើញដែលរងការជំទាស់នេះ គឺមិនមែនធ្វើឡើងដើម្បីកំណត់ ឬគូសបង្ហាញពីព្រំប្រទល់យុត្តាធិការទាំងនេះឡើយ ។ ទោះបីជាយ៉ាងណាក្ដី ដោយយោងលើប្រវត្តិពាក់ព័ន្ធនៃការចរចា ក៏ដូចជាសេចក្ដីថ្លែងការណ៍ និងការអនុវត្តន៍ជាបន្តបន្ទាប់មកទៀត បានបង្ហាញឱ្យឃើញថា ស.ច.ស បានសន្និដ្ឋានយ៉ាងត្រឹមត្រូវចំពោះករណីដែលថា ប្រទេសកម្ពុជាបានជ្រើសយកជម្រើសដកហូតនូវយុត្តាធិការពីតុលាការសាមញ្ញរបស់ខ្លួន លើឧក្រិដ្ឋកម្មនាសម័យខ្មែរក្រហម ដែលប្រការនេះ គ្មានមូលដ្ឋានអ្វីសម្រាប់ អ.ប.ជ ត្រូវធ្វើការកែតម្រូវដីកាដំណោះស្រាយ ឬធ្វើការប្រកាសសេចក្ដីថ្លែងការណ៍ស្ដីពីទស្សនៈរបស់ខ្លួន ចំពោះបញ្ហាច្បាប់ដែលកំពុងចោទឡើងនេះទេ ។ ដូច្នេះ ក្រុមការពារក្ដីសូមស្នើដោយគោរពដល់ អ.ប.ជ មេត្តាសម្រេចមិនទទួលយកសារណារបស់ ស.ម.ត.ដ ។ អ.ប.ជ មិនមែនជាវេទិកាតុលាការសមស្របដើម្បីធ្វើការកំណត់សម្រេច ឬក៏ផ្ដល់ការកែតម្រូវដូចដែលបានស្នើសុំនេះឡើយ ។

## II. សាវតារ

៣. នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០១៧ ស.ច.ស បានចេញដីកាដំណោះស្រាយនៃសំណុំរឿង០០៤/១ ដែលមានសំអាងហេតុពេញលេញ ដោយធ្វើការបញ្ជាក់ពីការសម្រេចច្រានចោលនូវរាល់បទចោទប្រកាន់ទាំងអស់ប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម[7] ។ នៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៧ អ.ប.ជ បាន

---

[6] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ៣២ ។

[7] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារ **D308/3** ។

សម្រេចផ្តល់សិទ្ធិដល់មេធាវី សំ សុគង់ ឱ្យដាក់សារណា "កម្រិតត្រឹមបញ្ហាជាក់លាក់អំពីជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា (ផ្នែក ២.១.១ នៃដីកាដំណោះស្រាយ)"[8] ។ នៅថ្ងៃទី ០៨ ខែ សីហា ស.ម.ត.ដ បានដាក់សារណាជាភាសាអង់គ្លេស និងនៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៧ ភាសាខ្មែរត្រូវបានដាក់ដាច់ដោយឡែកពីគ្នា[9] ។

## III. ចម្លើយតប

### ក. អ.ប.ជ មិនមែនជាវេទិកាសមស្របដើម្បីសម្រេចលើសារណា ស.ម.ត.ដ ទេ

៤. ស.ម.ត.ដ បានលើកឡើងថា "យុត្តាធិការនៃតុលាការកម្ពុជា គឺជាបញ្ហាមួយដែលត្រូវកំណត់ដោយតុលាការកម្ពុជាខ្លួនឯងផ្ទាល់ មិនមែនដោយ អ.វ.ត.ក នោះទេ"[10] ។ តាមការយល់ឃើញរបស់ ស.ម.ត.ដ ការសន្និដ្ឋាននៅក្នុងដីកាដំណោះស្រាយស្តីពីកង្វះយុត្តាធិការនៃតុលាការសាមញ្ញរបស់កម្ពុជា ធ្វើឡើងដើម្បីស្វះស្វែងឱ្យមានការ "ដកយុត្តាធិការចេញពីតុលាការកម្ពុជាធម្មតា តាមរយៈសិទ្ធិអំណាចតុលាការ"[11] ។ ផ្អែកលើមូលដ្ឋាននេះ ស.ម.ត.ដ បានស្នើសុំ អ.ប.ជ ឱ្យ "កែតម្រូវការសន្និដ្ឋានរបស់ដីកាដំណោះស្រាយ លើយុត្តាធិការរបស់តុលាការកម្ពុជាធម្មតាចំពោះឧក្រិដ្ឋកម្ម

---

8 សេចក្តីសម្រេចលើសំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិ ពាក់ព័ន្ធនឹងការដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ និងការអញ្ជើញឱ្យដាក់សារណា ចុះនៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៧, ឯកសារ **D308/3/1/8**, ត្រង់កថាខណ្ឌ ១២-១៣ ។

9 ក្រុមការពារក្តីកត់សម្គាល់ឃើញថាសារណារបស់ ស.ម.ត.ដ ត្រូវបានដាក់ដោយមេធាវីជាតិលោក សំ សុគង់, Emmanuel Jacomy និង Lyma Nguyen (*សូមមើល*, សារណារបស់ ស.ម.ត.ដ ត្រង់ក្របមុខ ផ្នែក "*ភាគីដាក់ឯកសារ*") ប៉ុន្តែជាក់ស្តែង មានតែមេធាវី សំ សុគង់ ម្នាក់គត់ដែលត្រូវបានផ្តល់សិទ្ធិឱ្យដាក់សារណានេះ ។ *សូមមើល*, សេចក្តីសម្រេចលើសំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិ ពាក់ព័ន្ធនឹងការដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ និងការអញ្ជើញឱ្យដាក់សារណា ចុះនៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៧, ឯកសារ **D308/3/1/8**, ត្រង់កថាខណ្ឌ ១២ ["*វាជាផលប្រយោជន៍នៃយុត្តិធម៌ក្នុងការផ្តល់ឱកាសឱ្យសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិបញ្ចេញនូវទស្សនរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលគាត់តំណាងឱ្យ*"] ។ នៅកថាខណ្ឌ១៣ ["*ដោយពិចារណាទៅលើហេតុផលខាងលើ ... អង្គបុរេជំនុំជម្រះស្នើឱ្យសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិដាក់សារណា*"] ។

10 សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ៤ ។

11 សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ៤ ។

សម័យខ្មែរក្រហម"[12] និងប្រកាសថា កម្រិតដែលតុលាការសាមញ្ញរបស់កម្ពុជាមានសមត្ថកិច្ចដើម្បីធ្វើការវិនិច្ឆ័យលើឧក្រិដ្ឋកម្មនាសម័យខ្មែរក្រហម គឺជាបញ្ហាមួយដែលត្រូវកំណត់ដោយតុលាការទាំងនោះ[13] ។

៥. បញ្ហាបឋមគឺថា សារណារបស់ ស.ម.ត.ដ ខ្វះភាពស៊ីសង្វាក់គ្នានៅផ្នែកខាងក្នុង និងនិយាយជាន់ដានគ្នា ។ ម្យ៉ាងទៅ ស.ម.ត.ដ ពោលអះអាងថា អ.វ.ត.ក គ្មានសមត្ថកិច្ចដើម្បីធ្វើការកំណត់បញ្ហាយុត្តាធិការតុលាការសាមញ្ញរបស់កម្ពុជា លើឧក្រិដ្ឋកម្មពីសម័យខ្មែរក្រហមនោះទេ ព្រោះវាជា "បញ្ហាមួយដែលត្រូវកំណត់ដោយតុលាការកម្ពុជាខ្លួនឯងផ្ទាល់ មិនមែនដោយ អ.វ.ត.ក" ឡើយ[14] ។ ម្យ៉ាងទៀតទៅ ស.ម.ត.ដ បានស្នើសុំ អ.ប.ជ ឱ្យធ្វើការកែតម្រូវលើការរកឃើញរបស់ ស.ច.ស ចំពោះបញ្ហានេះ[15] ក្រោមមូលដ្ឋានថា អ.ប.ជ គឺជា "វេទិកាតុលាការតែមួយគត់" ដែលអាចធ្វើដូច្នេះបាន ពីព្រោះ "តុលាការកម្ពុជាសាមញ្ញគ្មានសិទ្ធិពិនិត្យឡើងវិញលើដីកាដំណោះស្រាយនោះទេ"[16] ។

៦. ក្រុមការពារក្តីទទួលស្គាល់ថា មានតែតុលាការសាមញ្ញរបស់កម្ពុជាប៉ុណ្ណោះ ដែលអាចកំណត់ក្រោយគេបង្អស់ ពីបញ្ហាដែនយុត្តាធិការរបស់ខ្លួនលើឧក្រិដ្ឋកម្មនានានៅក្នុងសម័យខ្មែរក្រហម ។ ដូចបានសង្កេតយ៉ាងត្រឹមត្រូវនៅក្នុងសារណា[17] គ្មានខ្សែបន្ទាត់នៃសិទ្ធិអំណាចរវាង អ.វ.ត.ក និងតុលាការសាមញ្ញរបស់កម្ពុជាឡើយ[18] ។ "អ.វ.ត.ក គឺជាស្ថាប័នឯករាជ្យ ហើយដំណើរប្រតិបត្តិការរបស់ខ្លួនក៏ឯករាជ្យផងដែរនៅក្នុងរចនាសម្ព័ន្ធតុលាការជាតិ ដូច្នេះ អ.វ.ត.ក គ្មាន

---

[12] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ៧ ។

[13] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ៣២ ។

[14] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ៤ ។

[15] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ៧ ។

[16] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ៧ ។

[17] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ៤ ។

[18] *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច" សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អជសដ*, សេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទឱ្យនៅក្រៅឃុំ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩, ឯកសារ E39/5, ត្រង់កថាខណ្ឌ ១២ ។

សមត្ថកិច្ចវិនិច្ឆ័យលើចំណាត់ការរបស់ស្ថាប័នតុលាការផ្សេងឡើយ”[19] ។ ដូច អ.ប.ជ ធ្លាប់បានសន្និដ្ឋានកាលពីពេលកន្លងទៅថាខ្លួន “មិនឃើញមានបទប្បញ្ញត្តិណាមួយ ដែលចែងអំពីការទំនាក់ទំនងរវាង អ.វ.ត.ក ជាមួយស្ថាប័នតុលាការដទៃទៀតក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជាឡើយ”[20] ។ បានសេចក្តីថា អ.ប.ជ មិនមែនជាវេទិកាសមស្របដើម្បីផ្តល់តាមសំណើសុំកែតម្រូវដែលបានស្នើដោយ ស.ម.ត.ជ នោះទេ ។

៧. ម្យ៉ាងវិញទៀត សារណារបស់ ស.ម.ត.ជ បានបកស្រាយខុសនូវកម្មវត្ថុ គោលបំណង និងប្រសិទ្ធិភាពនៃការវិភាគរបស់ ស.ច.ស ចំពោះគោលជំហរ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ។ ស.ម.ត.ជ តវ៉ាថា ស.ច.ស មានបំណង “រារាំងតុលាការកម្ពុជាដោយគ្មានលក្ខខណ្ឌ មិនឱ្យអនុវត្តយុត្តាធិការ” លើរាល់ឧក្រិដ្ឋកម្មទាំងអស់នៃសម័យខ្មែរក្រហម[21] គឺជាការអានមិនត្រឹមត្រូវនូវលក្ខណៈ និងវិសាលភាពនៃដីកាសម្រេចដែលរងការជំទាស់ ។ ស.ច.ស គ្រាន់តែបានសន្និដ្ឋានថាកង្វះយុត្តាធិការនៃតុលាការសាមញ្ញរបស់កម្ពុជា “មិនត្រូវមានឥទ្ធិពលផ្នែកគោលនយោបាយមកលើការអនុវត្តឆន្ទានុសិទ្ធិរបស់យើង ពាក់ព័ន្ធទៅនឹងយុត្តាធិការបុគ្គលទេ”[22] ជាបញ្ហាសម្បទាអំណាចមួយដែលមិនត្រូវបាន ស.ម.ត.ជ ជំទាស់តវ៉ាឡើយ ។ ក្នុងន័យនេះ ស.ច.ស មិនមានបំណងសម្រេចជាស្ថាពរលើបញ្ហានានាដែលលើកឡើងដោយ ស.ម.ត.ជ ឬធ្វើយ៉ាងណាដើម្បីសន្មតពីការកាត់បន្ថយ ឬបន្ទច់បង្អាក់យុត្តាធិការតុលាការកម្ពុជានោះទេ ។

៨. ការវិភាគពីគោលជំហរ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា គឺត្រូវបានធ្វើឡើង “ដើម្បីបង្ហាញ

---

[19] *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ “ឌុច” សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/កសចស (អបជ០១)*, សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ “ឌុច” ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៧, ឯកសារ **C5/45**, ត្រង់កថាខណ្ឌ ១៩ ។

[20] *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ “ឌុច” សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/កសចស (អបជ០១)*, សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ “ឌុច” ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៧, ឯកសារ **C5/45**, ត្រង់កថាខណ្ឌ ១៧ ។

[21] សារណារបស់ ស.ម.ត.ជ ត្រង់កថាខណ្ឌ ៦ ។

[22] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ២៥ ។

អំពីផលវិបាកនៃការសន្និដ្ឋានថា ពុំមានយុត្តាធិការបុគ្គល និងផលប៉ះពាល់អ្វីខ្លះដែលអាចកើតមានចំពោះការអនុវត្តឆន្ទានុសិទ្ធិរបស់ ស.ច.ស នៅពេលសម្រេចលើកលែងការចោទប្រកាន់ក្នុងរឿងក្តីមួយ ដោយផ្អែកលើយុត្តាធិការបុគ្គលតែមួយមុខ"[23] ។ ការសន្និដ្ឋាននេះ គឺត្រូវបានរកឃើញជាមុនដើម្បីអាចឈានដល់ការវាយតម្លៃលើបញ្ហាយុត្តាធិការបុគ្គលបាន ហើយនៅទីបំផុត ធ្វើការបញ្ជាក់ពីដែនកំណត់ផ្អែកតាមលក្ខណៈឆន្ទានុសិទ្ធិរបស់ខ្លួនដែលខ្លួនមាន និងមិនបានសំដៅលើឆន្ទានុសិទ្ធតុលាការសាមញ្ញរបស់កម្ពុជាឡើយ[24] ។

៩. ការសំណូមពរណាមួយដែលផ្ទុយពីនេះ គឺជាការដើរចូលទៅក្នុងសភាពមិនប្រាកដប្រជា ។ ស.ម.ត.ដ ជំទាស់ថា អ.ប.ជ គួរតែធ្វើការកែតម្រូវការរកឃើញនានានៅក្នុងដីកាដំណោះស្រាយ ព្រោះបើសិនជាមានការអនុវត្តដូច្នេះមែន វានឹងទប់ស្កាត់ "តុលាការកម្ពុជាធម្មតាយ៉ាងច្បាស់លាស់មិនឱ្យដោះស្រាយដោយខ្លួនឯង មិនថាតុលាការទាំងនេះអាចអនុវត្តយុត្តាធិការ[លើខ្មែរក្រហម]ក្នុងរយៈពេលនេះ បានឬអត់នោះទេ"[25] ។ ស.ម.ត.ដ អះអាងថា "តុលាការកម្ពុជា*អាច*សម្រេចថា រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជាអនុញ្ញាតឱ្យ ឬក៏សឹងតែតម្រូវឱ្យមានការប្រើប្រាស់ដោយផ្ទាល់ នូវបទល្មើសដែលត្រូវបានទទួលស្គាល់ក្រោមច្បាប់ព្រហ្មទណ្ឌទំនៀមទំលាប់អន្តរជាតិសម្រាប់ឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម"[26] "*អាច* ... សម្រេចអនុញ្ញាតឱ្យមានការកាត់ទោសចំពោះឧក្រិដ្ឋកម្មដោយផ្អែកលើបទប្បញ្ញត្តិនានា ... ដែលត្រូវបានអនុម័តបន្ទាប់ពីមានការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ"[27] ឬថា "[តទៅថ្ងៃមុខ] កម្ពុជា*សឹងតែអាច*អនុម័តច្បាប់បន្ថែមដែលផ្តល់យុត្តាធិការកាន់តែច្បាស់លាស់បន្ថែមទៀតដល់តុលាការជាតិរបស់ខ្លួន លើឧក្រិដ្ឋកម្មក្នុង

---

23 ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១១ ។

24 ស.ច.ស មានឆន្ទានុសិទ្ធិទូលំទូលាយបំផុតក្នុងការកំណត់អំពីលក្ខណៈវិនិច្ឆ័យនៃយុត្តាធិការបុគ្គលនៅ អ.វ.ត.ក ។ *សូមមើល*, ទឡ្ហីករណ៍របស់ក្រុមការពារក្តីនៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ដែលធ្វើនៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៧, ឯកសារលេខ **D308/3/1/11** ត្រង់កថាខណ្ឌ ១០-១៥ ។

25 សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ៣១ ។

26 សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ៣១ (សង្កត់ន័យបន្ថែមត្រង់អក្សរទ្រេត) ។

27 សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ៣១ (សង្កត់ន័យបន្ថែមត្រង់អក្សរទ្រេត) ។

សម័យខ្មែរក្រហម"[28] ។ ដូចដែល អ.ប.ជ បានរម្លឹកជាច្រើនលើកច្រើនសារមករួចមកហើយថា មិនមានការតម្រូវឱ្យ អ.ប.ជ ធ្វើការពិចារណា ឬផ្តល់មតិយោបល់ណែនាំជាពិសេសលើស្ថានការណ៍បែបមិនប្រាកដប្រជាដូច្នោះទេ[29] ។ វាមិនមែនជាមុខងាររបស់ អ.ប.ជ ក្នុងការផ្តល់ហេតុផលតាមស្ថានការណ៍ដែលបង្ហាញដោយ ស.ម.ត.ដ ចំពោះករណីដែលថាតើប្រទេសកម្ពុជាអាច ឬ មិនអាច ក្នុងការសម្រេចពីការអនុវត្តយុត្តាធិការលើឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហមនៅពេលអនាគតនោះឡើយ ។

១០. នៅក្នុងបរិបទនៃបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ បញ្ហាតែមួយគត់ដែលនាំឱ្យ អ.ប.ជ ធ្វើការពិចារណា គឺថាតើ ស.ច.ស មានកំហុសដែរឬទេ ដោយសន្និដ្ឋានថាការអនុវត្តឆន្ទានុសិទ្ធិរបស់ពួកគាត់មិនត្រូវបានប៉ះពាល់ដោយគោលនយោបាយទូទៅណាមួយ ទាក់ទងនឹងយុត្តាធិការតុលាការសាមញ្ញរបស់កម្ពុជាលើឧក្រិដ្ឋកម្មពាក់ព័ន្ធ ។ ទោះបីជា ស.ច.ស មានកំហុសក្នុងការសន្និដ្ឋានថាតុលាការសាមញ្ញរបស់កម្ពុជាខ្វះយុត្តាធិការក៏ដោយ ក៏បន្ទុកធ្ងន់នៃការរកឃើញរបស់ពួកគាត់ គឺថាតើតុលាការសាមញ្ញរបស់កម្ពុជាមានយុត្តាធិការ ឬមិនមានឥទ្ធិពលដល់ការអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួនដូចម្តេចខ្លះទាក់ទងនឹងបញ្ហាយុត្តាធិការបុគ្គល ។ ស.ម.ត.ដ ហាក់ដូចជាមិនបានបង្ហាញពីការជំទាស់ទៅនឹងការរកឃើញនេះទេ ឬក៏ធ្វើការបង្ហាញឱ្យឃើញថាការរកឃើញទាក់ទងនឹងការអនុវត្តរបស់ប្រទេសកម្ពុជានៅលើសិទ្ធិអធិបតេយ្យភាពរបស់ខ្លួន បាននាំឱ្យ ស.ច.ស មានកំហុសឆ្គងណាមួយដែលអាចយកមកវិនិច្ឆ័យបានតាមសំណើដែលខ្លួនបានស្នើ ។

---

[28] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ៣១ (សង្កត់ន័យបន្ថែមត្រង់អក្សរទ្រេត) ។

[29] *សូមមើល*, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់សុំការបំភ្លឺ ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤, ឯកសារលេខ **D205/1/1/2** ត្រង់កថាខណ្ឌ ៨; សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ជំទាស់ទៅនឹងការបំភ្លឺរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីសុពលភាពនៃដីកាកោះដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារលេខ **D212/1/2/2** ត្រង់កថាខណ្ឌ ៦; សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់ស្នើសុំព័ត៌មានទាក់ទងនឹងករណីខ្វែងយោបល់គ្នា របស់សហចៅក្រមស៊ើបអង្កេត ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥, ឯកសារលេខ **D208/1/1/2** ត្រង់កថាខណ្ឌ ៨ ។

១១. សរុបសេចក្តីមក ប្រសិនបើមានពេលណាមួយដែលតុលាការសាមញ្ញរបស់កម្ពុជា អនាគតទៅគិតថា ខ្លួនមានសមត្ថកិច្ចកាត់ទោសលើឧក្រិដ្ឋកម្មពីសម័យខ្មែរក្រហមដែលស្ថិតនៅក្រៅវិសាលភាពនៃ អ.វ.ត.ក ក៏តុលាការកម្ពុជាទាំងនេះ មិនត្រូវបានចងកាតព្វកិច្ចភ្ជាប់នឹងការវិភាគរបស់ ស.ច.ស ក្នុងដីកាដំណោះស្រាយ និងក៏មិនត្រូវបានចងកាតព្វកិច្ចធ្វើការបញ្ឈប់នីតិវិធីរបស់ខ្លួនដោយសារតែការអំពាវនាវរបស់ អ.ប.ជ លើបញ្ហានេះដែរ ។ ទោះក្នុងករណីណាក៏ដោយ ដូចដែលនឹងត្រូវបានលើកជាអំណះអំណាងនៅក្នុង **ផ្នែក ខ** ខាងក្រោម ស្របនឹងសិទ្ធិអធិបតេយ្យរបស់ខ្លួនក្នុងការកំណត់យុត្តាធិការរបស់តុលាការសាមញ្ញលើឧក្រិដ្ឋកម្មនានា នេះគឺជាការចង្អុលបង្ហាញយ៉ាងច្បាស់ពីសំណាក់ប្រទេសកម្ពុជាចំពោះការដែលខ្លួនបានសម្រេចថា តុលាការសាមញ្ញរបស់កម្ពុជាមិនមានយុត្តាធិការលើឧក្រិដ្ឋកម្មទាំងអស់នៅសម័យខ្មែរក្រហមឡើយ ។ ក្រុមការពារក្តីយល់ឃើញថា រាល់ការអន្តរាគមន៍ដោយ អ.ប.ជ តាមរបៀបដែល ស.ម.ត.ដ បានខ្នះខ្នែងធ្វើការស្នើសុំ អាចប៉ះពាល់ដល់សិទ្ធិអធិបតេយ្យភាពរបស់កម្ពុជា ចំពោះការកំណត់ថាតុលាការសាមញ្ញរបស់ ខ្លួន ខ្វះយុត្តាធិការដើម្បីធ្វើការស៊ើបអង្កេត និងកាត់ទោសលើឧក្រិដ្ឋកម្មនាសម័យខ្មែរក្រហម ។

### ខ. ស.ច.ស បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថាតុលាការធម្មតារបស់កម្ពុជាខ្វះយុត្តាធិការលើឧក្រិដ្ឋកម្មទាំងអស់ពីសម័យខ្មែរក្រហម

១២. ស.ម.ត.ដ បានជំទាស់ថា ការអានជាទូទៅនូវឯកសារមូលដ្ឋាននានារបស់ អ.វ.ត.ក នាំឱ្យទាញការសន្និដ្ឋានបានថា តុលាការធម្មតារបស់កម្ពុជាមានយុត្តាធិការលើឧក្រិដ្ឋកម្មដែលស្ថិតនៅក្រៅវិសាលភាពនៃ អ.វ.ត.ក[30] ។ ស.ម.ត.ដ យល់ឃើញថា ការបកស្រាយរបស់ ស.ច.ស ចំពោះកិច្ចព្រមព្រៀងរបស់ អ.វ.ត.ក រត់បញ្ច្រាសគ្នាជាមួយនឹងកម្មវត្ថុ និងគោលបំណងរបស់ខ្លួន[31] ពីព្រោះវាធ្វើឱ្យកម្ពុជាបាត់បង់នូវសិទ្ធិផ្តាច់មុខ ក្នុងការក្នុងការកាត់ទោសអតីតសមាជិកខ្មែរក្រហម

[30] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ៨ ។ *សូមមើលផងដែរ*, សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ៩-៣១ ។

[31] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ១០-១៥ ។

លើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងនៃរបបនេះ[32] ។ ទោះជាយ៉ាងណាក្តី ដូចដែលនឹងត្រូវបានបង្ហាញនៅខាងក្រោមនេះ ក្រុមការពារក្តីយល់ឃើញថា រាល់ប្រភពឯកសារពិភាក្សាសំខាន់ៗទាំងអស់ ផ្តល់ការគាំទ្រការរកឃើញរបស់ ស.ច.ស នៅក្នុងដីកាដំណោះស្រាយ ។

១៣. ក្រុមការពារក្តីយល់ស្របថា ជាគោលការណ៍រដ្ឋមានយុត្តាធិការចម្បងលើឧក្រិដ្ឋកម្មទាំងឡាយណាដែលបានប្រព្រឹត្តនៅលើទឹកដីរបស់ខ្លួន[33] ហើយក៏យល់ស្របដែរថា គ្មានបទប្បញ្ញត្តិណាមួយនៅក្នុងកិច្ចព្រមព្រៀងរបស់ អ.វ.ត.ក បញ្ជាក់បដិសេធពីការបោះបង់នូវយុត្តាធិការតុលាការសាមញ្ញរបស់កម្ពុជាឱ្យបានច្បាស់លាស់ លើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងសម័យខ្មែរក្រហម ដែលស្ថិតនៅក្រៅដែនវិសាលភាពនៃ អ.វ.ត.ក នោះទេ[34] ។ បើទោះជាយ៉ាងដូច្នេះក៏ដោយចុះ ក៏ការអះអាងបន្ថែមផ្សេងទៀតរបស់ ស.ម.ត.ដ មិនអើពើនឹងការមើលឃើញរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានបញ្ជាក់អំឡុងពេលចរចាដើម្បីបង្កើត អ.វ.ត.ក ក៏ដូចជាការធ្វើសេចក្តីថ្លែងការណ៍ និងការអនុវត្តជាបន្តបន្ទាប់ គឺជាភស្តុតាងផ្ទុះបញ្ជាំងពីគោលបំណងដូច្នេះ ។

### *i. ស្ថាប័នរដ្ឋនានារបស់កម្ពុជាបានប្រើសិទ្ធិអធិបតេយ្យភាពរបស់ខ្លួន*

១៤. ប្រទេសមួយដែលមានអធិបតេយ្យភាព មានអំណាចក្នុងការអនុវត្តសិទ្ធិរបស់ខ្លួនដើម្បីសម្រេចលើការកាត់ទោស ដោយពិចារណាទៅលើកត្តាមួយចំនួន ដូចជា ការផ្សះផ្សាជាតិ ស្ថិរភាពនយោបាយ ឬផលប្រយោជន៍យុត្តិធម៌ ។ អំណាចរបស់រដ្ឋក្នុងការអនុវត្តនូវយុត្តាធិការលើរឿងក្តីព្រហ្មទណ្ឌ "គឺវាស្ថិតនៅក្នុងអធិបតេយ្យភាពរបស់ខ្លួន"[35] ។ សេចក្តីសម្រេចនានាលើបទល្មើសព្រហ្មទណ្ឌថ្នាក់ជាតិ ត្រូវបានត្រួតពិនិត្យមើលដោយរដ្ឋជាម្ចាស់ប្រទេស "ជាប្រវត្តិសាស្ត្រ ... វាជាការ

[32] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ១០-១២ ។

[33] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ១១ ។

[34] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ១០ ។

[35] *រឿងក្តី the S.S. "Lotus" (ប្រទេសបារាំង ទល់នឹង តួកគី),* (ការបោះពុម្ពផ្សាយរបស់ P.C.I.J ឆ្នាំ១៩២៧), សាលដីកាលេខ: ០៩ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩២៧, ត្រង់ទំព័រ ១៩ (**ភ្ជាប់ជាឯកសារសំអាងលេខ ២**) ។

អនុវត្តន៍នូវអធិបតេយ្យភាពជាតិមួយ”[36] ។ រដ្ឋមួយ ត្រូវបានផ្តល់សម្បទាដើម្បីឱ្យធ្វើការ “អនុម័តនូវគោលការណ៍ទាំងឡាយដែលខ្លួនយល់ថាវាមានភាពល្អប្រសើរ និងសមស្របបំផុត” សម្រាប់ប្រទេសជាតិ[37] ។

១៥. ខណៈដែលច្បាប់ទំនៀមទម្លាប់អន្តរជាតិ អាចអនុញ្ញាតឱ្យរដ្ឋមួយធ្វើការកាត់ទោសលើបទល្មើសអន្តរជាតិក៏ដោយ ប៉ុន្តែនៅរាល់ករណីទាំងអស់ ច្បាប់នេះមិនបានតម្រូវឱ្យរដ្ឋមានកាតព្វកិច្ចត្រូវតែកាត់ទោសលើឧក្រិដ្ឋកម្មនានា រួមទាំងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ[38] ។ មូលដ្ឋានទាំងឡាយ សម្រាប់ការអនុវត្តយុត្តាធិការគួរតែមានភាពទូលំទូលាយគ្រប់គ្រាន់ និងមានប្រសិទ្ធភាពដើម្បីធានាថា រដ្ឋមួយដែលមានអធិបតេយ្យភាពក្នុងការនាំខ្លួនជនណាក៏ដោយមកផ្តន្ទាទោសនៅចំពោះមុខតុលាការជាតិរបស់ខ្លួន ដោយមិនខ្វល់ថាជនទាំងនោះមានជាតិសាសន៍អ្វីឡើយ[39] ។

---

[36] អត្ថបទរៀបរៀងឡើងដោយ C. Bassiouni, *សេចក្តីណែនាំអំពីច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* (បោះពុម្ពលើកទីពីរ ដោយ Martinus Nijhoff ឆ្នាំ ២០១២) ត្រង់ទំព័រ ៥០៩ (**ភ្ជាប់ជាឯកសារសំអាងលេខ ៣**) ។

[37] *រឿងក្តី the S.S. “Lotus” (ប្រទេសបារាំង ទល់នឹង តួកគី),* (ការបោះពុម្ពផ្សាយរបស់ P.C.I.J ឆ្នាំ១៩២៧), សាលដីកាលេខ: ០៩ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩២៧, ត្រង់ទំព័រ ១៩ ។

[38] *រឿងក្តី* R *ទល់នឹង Bow Street Stipendiary Magistrate និងអ្នកផ្សេងទៀត, ex parte Pinochet Ugarte* (ដោយអង្គការលើកលែងទោសអន្តរជាតិ និងការធ្វើអន្តរាគមន៍មួយចំនួនទៀត) [ឆ្នាំ១៩៩៨] ៤ ទាំងអស់ ER 897, ត្រង់ទំព័រ ៩២៩-៣០ (រៀបរៀងដោយ Lord Lloyd នៃ Berwick) [“ពន្លឺបន្ថែមទៀតត្រូវបានស្តែងឡើងតាមរយៈការអនុវត្តរបស់រដ្ឋដោយការអនុម័តយ៉ាងទូលំទូលាយនូវការលើកលែងទោសចំពោះជនដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ... មួយចំនួននៃជនទាំងនេះ បានទទួលការផ្តល់ការលើកលែងទោសតាមរយៈអង្គការសហប្រជាជាតិ ដែលទង្វើនេះ គឺជាមធ្យោបាយមួយដើម្បីស្តារឡើងវិញនូវសន្តិភាព និងរដ្ឋាភិបាលប្រជាធិបតេយ្យ ។ ... ការនេះ មិនត្រូវបានធ្វើការជំទាស់ឡើយថាការលើកលែងទោសទាំងនេះ គឺវាផ្ទុយពីច្បាប់អន្តរជាតិដោយហេតុផលនៃការបរាជ័យក្នុងការកាត់ទោសជនដែលម្នាក់ៗនោះទេ ។ ... ការអនុវត្តរបស់រដ្ឋដូច្នេះ មិនគាំទ្រនូវការមានកាតព្វកិច្ចធ្វើបត្យាប័ន ឬកាត់ទោស គ្រប់ករណីទាំងអស់នោះឡើយ”] (**ភ្ជាប់ជាឯកសារសំអាងលេខ ៤**) ។

[39] *សូមមើល,* អនុសញ្ញាទីក្រុងហ្សឺណែវ ដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថានភាពអ្នករងរបួស និងអ្នកជំងឺក្នុងកងកម្លាំងប្រដាប់អាវុធនៅសមរភូមិ (អនុម័តថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ចូលជាធរមាន នៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៥០), វ៉ុល ៧៥ លេខសម្គាល់: UNTS 31 ត្រង់មាត្រា ៤៩ (**ភ្ជាប់ជាឯកសារសំអាងលេខ ៥**) ។ អនុសញ្ញាទីក្រុងហ្សឺណែវ ដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថានភាពអ្នករងរបួស អ្នកជំងឺ និងជនរងគ្រោះដោយលិចកប៉ាល់នៅក្នុងកងកម្លាំងប្រដាប់អាវុធនៅតំបន់សមុទ្រ (អនុម័តថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ចូលជាធរមាន នៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៥០), វ៉ុល ៧៥ លេខសម្គាល់: UNTS 85 ត្រង់មាត្រា ៥០ (**ភ្ជាប់ជាឯកសារសំអាងលេខ ៦**) ។ អនុសញ្ញាទីក្រុងហ្សឺណែវ

ការពិតដែលរាជរដ្ឋាភិបាលកម្ពុជាបានជ្រើសប្រើប្រាស់នូវអធិបតេយ្យភាព និងជំរុញឱ្យមានការអនុវត្តច្បាប់ព្រហ្មទណ្ឌរបស់ខ្លួនតាមរយៈការចុះហត្ថលេខាលើកិច្ចព្រមព្រៀង អ.វ.ត.ក ដែលនាំឱ្យមានការបង្កើត អ.វ.ត.ក ក៏ទង្វើនេះមិនមែនជាការបង្កើនកាតព្វកិច្ច (ហួសពីអ្វីដែលត្រូវបានបង្កើតឡើងដោយច្បាប់ទំនៀមទម្លាប់ ឬច្បាប់អនុសញ្ញា) សម្រាប់កម្ពុជាដែរ ។ នឹងគ្មានការសន្មតទេថាប្រទេសកម្ពុជាបាន ឬមិនបានអនុវត្តសិទ្ធិអធិបតេយ្យភាពរបស់ខ្លួនត្រឹមត្រូវ នៅពេលសម្រេចទប់ស្កាត់មិនឱ្យបន្តការកាត់ទោសបន្ថែមទៀត ចំពោះបទល្មើសដែលកើតឡើងនៅសម័យខ្មែរក្រហម ។ ដូចដែលត្រូវបានគេទទួលស្គាល់នៅក្នុងស្ថានការណ៍ក្រោយមានជម្លោះ ទម្រង់នៃការកាត់ទោសលើបទល្មើសព្រហ្មទណ្ឌ គ្រាន់តែជាផ្នែកមួយប៉ុណ្ណោះនៃ "ដំណើរការរបស់ប្រទេសមួយ ... [ក្នុងការ]ផ្សះផ្សាជាតិ"[40] ។ ជាការពិតណាស់ "សង្គមទាំងឡាយដែលទើបងើបចេញពីការគ្រប់គ្រងដ៏ឃោរឃៅ ជម្លោះស៊ីវិល និងសង្គ្រាមបានប្រើប្រាស់វិធីសាស្ត្រ ព្រមទាំងរបៀបខុសៗគ្នាតាមរយៈការអនុវត្តបែបគ្មានការកាត់ទោស និងជម្រើសប្រើផ្លូវច្បាប់ ហើយជាវិធីសាស្ត្រដែលបំពេញនូវបំណងដើម្បីសម្រេចបាននូវយុត្តិធម៌ក្រោយជម្លោះ"[41] ។ ការទទួលស្គាល់បែបនេះ ហាក់ដូចជាបានផ្ដល់ជាមូលដ្ឋានគ្រឹះសម្រាប់វិធីសាស្ត្ររបស់កម្ពុជា ដែលស្វះស្វែងឱ្យមានដំណើរការ

---

ទាក់ទិនទៅនឹងការប្រព្រឹត្តចំពោះឈ្លើយសឹក (អនុម័តថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ចូលជាធរមាន នៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៥០), វ៉ុល ៧៥ លេខសម្គាល់: UNTS 135 ត្រង់មាត្រា ១២៩ (**ភ្ជាប់ជាឯកសារសំអាងលេខ ៧**) ។ អនុសញ្ញាទីក្រុងហ្សឺណែវ ទាក់ទងនឹងការការពារជនស៊ីវិលក្នុងពេលមានសង្គ្រាម (អនុម័តថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ចូលជាធរមាន នៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៥០), វ៉ុល ៧៥ លេខសម្គាល់: UNTS 287 ត្រង់មាត្រា ១៤៦ (**ភ្ជាប់ជាឯកសារសំអាងលេខ ៨**) ។ ពិធីសារបន្ថែម I ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលធ្វើនៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩, និងដែលពាក់ព័ន្ធទៅនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធអន្តរជាតិ (អនុម័តថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ១៩៧៧ ចូលជាធរមាននៅថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ១៩៧៨), វ៉ុល 1125 លេខសម្គាល់៖ UNTS 3 មាត្រា ៨៦ (**ភ្ជាប់ជាឯកសារសំអាងលេខ ៩**) ។

[40] អត្ថបទរៀបរៀងឡើងដោយ M.W. Hanna, *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ - លេខ III* ស្ដីពី: ការអនុវត្តអន្តរជាតិ (ដោយ M. Cherif Bassiouni បោះពុម្ពលើកទី៣៖ Martinus Nijhoff ឆ្នាំ២០០៨), ជំពូក ៣.២, ទិដ្ឋភាពទូទៅផ្នែកប្រវត្តិសាស្ត្រនៃការកាត់ទោសថ្នាក់ជាតិលើឧក្រិដ្ឋកម្មអន្តរជាតិ ត្រង់ទំព័រ ៣០០ (**ភ្ជាប់ជាឯកសារសំអាងលេខលេខ ១០**) ។

[41] អត្ថបទរៀបរៀងឡើងដោយ M.W. Hanna, *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ - លេខ III* ស្ដីពី: ការអនុវត្តអន្តរជាតិ (ដោយ M. Cherif Bassiouni បោះពុម្ពលើកទី៣៖ Martinus Nijhoff ឆ្នាំ២០០៨), ជំពូក ៣.២, ទិដ្ឋភាពទូទៅផ្នែកប្រវត្តិសាស្ត្រនៃការកាត់ទោសថ្នាក់ជាតិលើឧក្រិដ្ឋកម្មអន្តរជាតិ ត្រង់ទំព័រ ៣០០-០១ ។

កាត់ទោសលើបទល្មើសព្រហ្មទណ្ឌក្នុងកម្រិតមួយ តាមរយៈ អ.វ.ត.ក ហើយស្របពេលជាមួយគ្នា ប្រើប្រាស់នូវធនធានដែលនៅសល់ និងមានកម្រិតរបស់ខ្លួនក្នុងការបន្តគម្រោងកម្មវិធីផ្តល់ការអប់រំ និងសកម្មភាពគាំទ្រជនរងគ្រោះ ដើម្បីស្តារនីតិសម្បទាទាក់ទងនឹងអតីតកាលសោកនាដកម្មដែលខ្លួនបានទទួលរង[42] ។

### *ii. សេចក្តីសន្និដ្ឋានរបស់ ស.ច.ស ស្របជាមួយនឹងប្រវត្តិនៃការចរចារបស់ អ.វ.ត.ក*

១៦. ស.ម.ត.ដ ក៏បានអះអាងថា សេចក្តីសន្និដ្ឋានរបស់ ស.ច.ស ដែលថាតុលាការធម្មតារបស់កម្ពុជាខ្វះយុត្តាធិការលើឧក្រិដ្ឋកម្មនាក្នុងសម័យខ្មែរក្រហមទាំងអស់ វាផ្ទុយទៅនឹងស្ថានការណ៍នានាដែលមាននៅក្នុងការបញ្ចប់កិច្ចព្រមព្រៀងរបស់ អ.វ.ត.ក[43] ។ ចំណុចជាក់លាក់ ស.ម.ត.ដ យល់ថាមានប្រភពសំខាន់ៗជាច្រើន គាំទ្រអំណះអំណាងរបស់ពួកគេដែលថាតុលាការសាមញ្ញរបស់កម្ពុជាមានយុត្តាធិការលើឧក្រិដ្ឋកម្មនាសម័យខ្មែរក្រហម ហើយថា "ការបកស្រាយរបស់ ស.ច.ស នាំឱ្យមានលទ្ធផលកាន់តែមិនច្បាស់លាស់ថែមទៀត ដោយបង្កើតការលើកលែងទោសជាទូទៅក្នុងការរំលោភលើកម្មវត្ថុ និងគោលបំណងនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក"[44] ។ ផ្ទុយទៅវិញក្រុមការពារក្តីយល់ឃើញថា រាល់ប្រភពឯកសារពិភាក្សាសំខាន់ៗទាំងអស់ពាក់ព័ន្ធនឹងប្រវត្តិនៃការចរចារបស់ អ.វ.ត.ក ដែលនឹងត្រូវពិភាក្សាខាងក្រោម ផ្តល់ការគាំទ្រយ៉ាងខ្លាំងក្លាដល់ការអះអាង

---

[42] *សូមមើលជាឧទាហរណ៍,* មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ("ជាគំនិតផ្តួចផ្តើមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងទេសចរណ៍ បង្កើតឡើងដើម្បី ឧទ្ទិសដល់ការចងចាំ ការផ្សះផ្សា និងការកសាងសន្តិភាព ហើយនឹងសម្រេចនូវបំណងទាំងនេះ តាមរយៈការសិក្សាអំពីសន្តិភាព និងការអប់រំពីអំពើប្រល័យពូជសាសន៍"), អាចចូលមើលបាននៅ: http://www.d.dccam.org/Projects/AVPC/avpc.htm); វិទ្យាស្ថានស្ពឺកវិត ("សារមន្ទីរនៃការចងចាំ, ការស្រាវជ្រាវព្រមទាំងជាមជ្ឈមណ្ឌលអភិវឌ្ឍន៍គោលនយោបាយជាតិ និងសាលាសិក្សាពីអំពើប្រល័យពូជសាសន៍ ជម្លោះ និងសិទ្ធិមនុស្ស"), អាចចូលមើលបាននៅ: http://www.cambodiasri.org/about) ។ *សូមមើល,* អត្ថបទស្រាវជ្រាវរបស់ J. D. Ciorciari និង J. Ramji-Nogales ស្តីពី 'មេរៀនពីបទពិសោធន៍កម្ពុជាដោយសេចក្តីពិតនិងការផ្សះផ្សា' ដោយ: Buffalo Human Rights Law Review ធ្វើនៅខែ កញ្ញា ឆ្នាំ ២០១២, អាចចូលមើលបាននៅទំព័រ ២០-២៥ (ពិពណ៌នាពីគម្រោងអប់រំសាធារណៈ ស្តីពីការសន្ទនាក្នុងសហគមន៍ និងពិធីបុណ្យរំឭកការចងចាំ និងពិធីបុណ្យសាធារណៈដទៃទៀត) (**ភ្ជាប់ជាឯកសារសំអាងលេខ ១១**) ។

[43] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ១៧-២៥ ។

[44] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ១៣-១៥ ។

ពីការដែលប្រទេសកម្ពុជាបានសម្រេចធ្វើការដាក់កម្រិតតុលាការសាមញ្ញរបស់ខ្លួន និងដកហូត យុត្តាធិការថ្នាក់ជាតិចំពោះឧក្រិដ្ឋកម្មទាំងអស់នាសម័យខ្មែរក្រហម ។

១៧. ដំបូង សំណើសុំជំនួយរបស់រាជរដ្ឋាភិបាលកម្ពុជា[45] គឺជាសញ្ញាច្បាស់លាស់មួយនៃការទទួលស្គាល់ពីកម្ពុជាថា តុលាការរបស់ខ្លួនខ្វះសមត្ថភាពពាក់ព័ន្ធ និងការបញ្ជាក់យ៉ាងច្បាស់នៃការអនុវត្តសិទ្ធិអធិបតេយ្យលើការកម្រិតតុលាការសាមញ្ញរបស់ខ្លួន និងដកយុត្តាធិការថ្នាក់ជាតិលើរាល់ឧក្រិដ្ឋកម្មទាំងអស់នៅសម័យខ្មែរក្រហម ។

១៨. ទីពីរ ស.ម.ត.ដ បានដកស្រង់នូវរបាយការណ៍ឆ្នាំ១៩៩៧ របស់គណៈកម្មាធិការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា (“របាយការណ៍របស់លោក Hammarberg”)[46] ដោយចោទឡើងថា របាយការណ៍នេះបានចងក្រងឯកសារបង្ហាញពីការព្រួយបារម្ភយ៉ាងធ្ងន់ធ្ងរលើបញ្ហា “និទណ្ឌភាពដែលនៅតែបន្តលើអំពើឃោរឃៅដែលបានប្រព្រឹត្តដោយខ្មែរក្រហម”[47] និងបានអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជាឱ្យធ្វើការផ្តន្ទាទោសនូវរាល់ “ជនទាំងអស់ដែលបានប្រព្រឹត្តអំពើរំលោភសិទ្ធិមនុស្ស”[48] គឺជាការអះអាងដោយកាត់យល់ខុស ។ របាយការណ៍របស់លោក Hammarberg ត្រូវបានចេញផ្សាយរយៈពេលប្រាំមួយ(៦)ខែ មុនការដាក់សំណើសុំជំនួយរបស់រាជរដ្ឋាភិបាលកម្ពុជាទៅកាន់អង្គការសហប្រជាជាតិសម្រាប់ធ្វើការកាត់ទោសជនដែលដល់ខ្មែរក្រហម ពោលគឺនៅចំពេល

---

[45] *សូមមើល*, លិខិតចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៧ ពីនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃប្រទេសកម្ពុជា ផ្ញើជូនអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ, ឯកសារអង្គការសហប្រជាជាតិលេខ A/51/930 S/1997/488 ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៧ (**ភ្ជាប់ជាឯកសារសំអាងលេខ ១២**) ។

[46] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ១៨ ។

[47] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ១៨ *យោងទៅលើ* “របាយការណ៍ពីតំណាងពិសេសរបស់អគ្គលេខាធិការ [អង្គការសហប្រជាជាតិ]សម្រាប់សិទ្ធិមនុស្សនៅកម្ពុជា លោក តូម៉ាស ហាម៉ាប៊ឹក (Thomas Hammarberg) ដែលបានដាក់ជូនតាមសេចក្តីសម្រេចរបស់មហាសន្និបាតលេខ 1996/54,” ឯកសារអង្គការសហប្រជាជាតិលេខ E/CN.4/1997/85 ធ្វើថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៧ (“របាយការណ៍របស់លោក Hammarberg”) កថាខណ្ឌ ៧ (**ភ្ជាប់ជាឯកសារសំអាងលេខទី ១៣**) ។

[48] សារណារបស់ ស.ម.ត.ដ កថាខណ្ឌ ១៨ *ដោយយោងទៅលើ* របាយការណ៍របស់លោក Hammarberg កថាខណ្ឌ ៨ ។

ដែលមានការពិភាក្សាអំពីការបង្កើត អ.វ.ត.ក មិនទាន់ត្រូវបានចាប់ផ្តើមនៅឡើយ[49] ។ ម្យ៉ាងទៀត ទោះបីរបាយការណ៍នេះអាចជាភស្តុតាងបង្ហាញពីចេតនារបស់កម្ពុជាទាក់ទងនឹង អ.វ.ត.ក ក៏ដោយ[50] ការពិនិត្យឱ្យកាន់តែកៀកលើបញ្ហានេះ បង្ហាញឱ្យឃើញពីកម្សោយនៃការអះអាងដែលបានលើកឡើង ។ ផ្នែកដែលត្រូវបានដកស្រង់ មិនស្ថិតក្នុងសុពលភាពនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក នោះទេ ប៉ុន្តែវាទាក់ទងទៅនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តទៅនៅក្រោយសម័យខ្មែរក្រហម ជាអំឡុងពេលដែលតុលាការសាមញ្ញរបស់កម្ពុជាមានយុត្តាធិការលើ[51] ។

១៩. ទីបី ការយោងសេចក្តីរបស់ ស.ម.ត.ដ ពីក្នុងឯកសារអង្គការសហប្រជាជាតិនៅក្នុងសេចក្តីសម្រេចរបស់មហាសន្និបាតលេខ ៥២/១៣៥ ដែលបានអនុម័តដើម្បី "ដោះស្រាយស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា និងដើម្បីឆ្លើយតបទៅនឹងសំណើសុំជំនួយរបស់រដ្ឋាភិបាលកម្ពុជា" ក្នុងការនាំខ្លួនខ្មែរក្រហមមកធ្វើការវិនិច្ឆ័យទោស[52] ត្រូវតែធ្វើការពិនិត្យដោយប្រុងប្រយ័ត្នផងដែរ ។ ផ្ទុយពីការថ្លែងរបស់ ស.ម.ត.ដ[53] មហាសន្និបាតមិនបានអំពាវនាវឱ្យរាជរដ្ឋាភិបាលកម្ពុជាធ្វើការកាត់ទោសជនដែលដល់ខ្មែរក្រហមទាំងអស់ឡើយ ។ ផ្ទុយទៅវិញ សេចក្តីសម្រេចរបស់មហាសន្និបាត

---

49 *សូមមើល*, លិខិតចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៧ ពីនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃប្រទេសកម្ពុជា ផ្ញើជូនអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ, ឯកសារអង្គការសហប្រជាជាតិលេខ A/51/930 S/1997/488 ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៧ ។

50 សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ១៨ ។

51 របាយការណ៍នេះ បានបង្ហាញពីការព្រួយបារម្ភយ៉ាងខ្លាំងចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយពួកខ្មែរក្រហម *បន្ទាប់ពីការដួលរលំ*នៃរបបកម្ពុជាប្រជាធិបតេយ្យ (ពោលគឺនៅក្រោយពីវិសាលភាពពេលវេលាពាក់ព័ន្ធ ទាក់ទងនឹងសារណារបស់ ស.ម.ត.ដ នេះ) និងទៅលើនិទណ្ឌភាពនៃជនដែលបានរំលោភបំពានសិទ្ធិមនុស្ស "ជាពិសេស សមាជិកកងទ័ព ប៉ូលីស និងកងកម្លាំងប្រដាប់អាវុធផ្សេងៗទៀត" ។ *សូមមើល*, របាយការណ៍របស់លោក Hammarberg, ត្រង់កថាខណ្ឌ ៧១ ។ *សូមមើលផងដែរ, អានជាទូទៅ*, របាយការណ៍របស់លោក Hammarberg, ត្រង់កថាខណ្ឌ ៦១-៨០ ដែលបានពិពណ៌នាអំពីកត្តា*ជាក់ស្តែង* និងតាម*ផ្លូវច្បាប់* លើបញ្ហានិទ្ទណ្ឌភាព ឬអសមត្ថភាពក្នុងការផ្តន្ទាទោសចំពោះអ្នករំលោភបំពានសិទ្ធិមនុស្សនៅកម្ពុជា ។

52 សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ២០ *យោងទៅលើ* សេចក្តីសម្រេចរបស់មហាសន្និបាតលេខ ៥២/១៣៥ "ស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា," ឯកសារអង្គការសហប្រជាជាតិលេខ A/RES/52/135, ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ("សេចក្តីសម្រេចរបស់មហាសន្និបាតលេខ ៥២/១៣៥") (**ភ្ជាប់ជាឯកសារសំអាងលេខទី ១៤**) ។

53 *សូមមើល*, សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ២០ ។

បាន i) កត់សម្គាល់ដោយកង្វល់ពីការដែលមិនមានមេដឹកនាំខ្មែរក្រហមរូបណា ត្រូវបាននាំខ្លួនយកមកវិនិច្ឆ័យទោសចំពោះឧក្រិដ្ឋកម្មនានា ដែលត្រូវបានប្រព្រឹត្តទៅនៅបន្ទាប់ពីការដួលរលំនៃរបបនេះ (ពោលគឺនៅក្រោយពីវិសាលភាពពេលវេលាពាក់ព័ន្ធនឹងសារណារបស់ ស.ម.ត.ដ)[54] ii) កត់សម្គាល់ពីលទ្ធភាពនៃការតែងតាំងក្រុមអ្នកជំនាញជាមធ្យោបាយដើម្បីនាំឱ្យមាន "ការផ្សះផ្សាជាតិ ការពង្រឹងនូវលទ្ធិប្រជាធិបតេយ្យ និងដើម្បីធ្វើការដោះស្រាយលើបញ្ហានៃការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗ"[55] ។ ជាក់ស្តែង ភាគីដែលចូលរួមក្នុងប្រវត្តិចរចារបស់ អ.វ.ត.ក គឺសុទ្ធតែមិនបានព្យាករទុកជាមុន ពីការដោះស្រាយបញ្ហានៃការមានយុត្តាធិការបន្ថែមលើឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម និងក៏មិនបានប្រមើលមើលទុកជាមុនដែរ ពីការមិនកាត់ទោសលើឧក្រិដ្ឋកម្មទាំងនោះ៖ កិច្ចពិភាក្សាទាំងនោះបានលើកឡើងត្រឹមតែថាតើមានមធ្យោបាយល្អបំផុតអ្វីខ្លះ ផ្តល់ប្រយោជន៍ដល់ការផ្សះផ្សាជាសត្យានុម័ត ការបង្រួបបង្រួមជាតិ និងយុត្តិធម៌ប៉ុណ្ណោះ ។

២០. ចុងក្រោយ ស.ម.ត.ដ បានដកស្រង់របាយការណ៍ដែលរៀបចំឡើងដោយក្រុមអ្នកជំនាញរបស់អសប[56] ជាភស្តុតាងបញ្ជាក់ថា តុលាការសាមញ្ញរបស់កម្ពុជាមានយុត្តាធិការលើឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម[57] ។ ទោះជាយ៉ាងណាក្តី អាណត្តិរបស់ក្រុមអ្នកជំនាញ គឺបង្កើតឡើងដើម្បីធ្វើការកំណត់ "នូវចរិតលក្ខណៈនៃបទឧក្រិដ្ឋទាំងឡាយដែលបានប្រព្រឹត្តដោយ*មេដឹកនាំ*ខ្មែរក្រហមនៅកំឡុងឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ... និងស្វែងរកជម្រើសផ្នែកច្បាប់នានាដើម្បីនាំខ្លួន*ពួកគេ*មកវិនិច្ឆ័យទោសនៅចំពោះមុខយុត្តាធិការអន្តរជាតិ ឬយុត្តាធិការថ្នាក់ជាតិ"[58] ។ ដោយមិនគិតទៅដល់

---

54 សេចក្តីសម្រេចរបស់មហាសន្និបាតលេខ ៥២/១៣៥ ត្រង់កថាខណ្ឌ ១៥ ។

55 សេចក្តីសម្រេចរបស់មហាសន្និបាតលេខ ៥២/១៣៥ ត្រង់កថាខណ្ឌ ១៦ ។

56 របាយការណ៍របស់ក្រុមជំនាញសម្រាប់ប្រទេសកម្ពុជា ដែលបានបង្កើតឡើងផ្អែកតាមសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ៥២/១៣៥, ឯកសារ អសប លេខ A/53/850-S/1999/231 ចុះនៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ១៩៩៩ ("របាយការណ៍របស់ក្រុមជំនាញ") (**ភ្ជាប់ជាឯកសារសំអាងលេខ ១៥**) ។

57 សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ២១-២២ ។

58 *សំណុំរឿង មាស មុត, រឿងក្តីលេខ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស*, លិខិតដូចគ្នា ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ១៩៩៩ ពីអគ្គលេខាធិការ អសប ជូនប្រធានមហាសន្និបាត និងប្រធានក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ, ឯកសារ

ថាតើការកាត់ទោសត្រូវបានធ្វើចំពោះមុខយុត្តាធិការអន្តរជាតិ ឬយុត្តាធិការថ្នាក់ជាតិនោះទេ ការផ្តោតសំខាន់ដែលមិនអាចប្រកែកបាន គឺការផ្តន្ទាទោសលើអតីតមេដឹកនាំខ្មែរក្រហម (វាផ្ទុយនឹងការសំដៅលើការកាត់ទោសលើជនដែលខ្មែរក្រហមទាំងអស់) ។ វាប្រាកដណាស់ថា អ.វ.ត.ក គឺជាផ្លែផ្កាទទួលបានពីការជ្រើសតាំងនោះ ។

២១. ក្រុមអ្នកជំនាញយល់ច្បាស់ណាស់ថាការកាត់សេចក្តីនៅចំពោះមុខតុលាការកម្ពុជា មិនមែនជាជម្រើសដែលអាចយកជាការបានឡើយ[59] ។ ក្រុមនេះក៏បានសន្និដ្ឋានដូច្នេះថា ការកាត់សេចក្តីលើជនដែលខ្មែរក្រហមភាគច្រើន គឺមិនអាចរ៉ាប់រងទៅរួចទាំងផ្នែកហិរញ្ញវត្ថុ និងភស្តុភារ ដែលវាអាចជាការរាំងស្ទះដល់ការផ្សះផ្សាជាតិ ហើយថាការទទួលខុសត្រូវរបស់ជនដែលថ្នាក់ទាប គឺជាបញ្ហាច្បាប់ដ៏ស្មុគស្មាញមួយ[60] ។ សរុបសេចក្តីមក របាយការណ៍ក្រុមអ្នកជំនាញគាំទ្រយ៉ាងពេញទំហឹងចំពោះសំណើដែលស្នើថា អ.វ.ត.ក ជាតុលាការមួយបង្កើតឡើងដើម្បីវិនិច្ឆ័យទោសមេដឹកនាំធំៗមួយចំនួន និងតុល្យភាពគោលបំណងសំខាន់ៗនៃយុត្តិធម៌អន្តរកាល ។

### *iii. មិនមានការចែងឡើយ អំពីយន្តការផ្ទេររឿងក្តី*

២២. ស.ម.ត.ដ បានអះអាងថា នៅអំឡុងពេលនៃការចរចា (ចាប់ពីមានសំណើសុំជំនួយរបស់ប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៧ មក) "តុលាការកម្ពុជាពុំមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីបំពេញដំណើរការជំនុំជម្រះ"[61] ទេ ។ តាមការលើកឡើងរបស់ ស.ម.ត.ដ វាជាភស្តុតាងបង្ហាញពីអវត្តមាននូវយន្តការផ្ទេររឿងក្តី (ស្រដៀងគ្នាទៅនឹងតុលាការ ICTR និងតុលាការ ICTY) នៅក្នុងកិច្ច

---

អសប លេខ A/53/850 ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ១៩៩៩, ឯកសារ [អ.វ.ត.ក] **D181/2.15** ត្រង់ទំព័រ ១ (សង្កត់ន័យបន្ថែមត្រង់អក្សរទ្រេត) ។

[59] របាយការណ៍របស់ក្រុមជំនាញ ត្រង់កថាខណ្ឌ ១៣២ ["ក្រុមជំនាញយល់ឃើញថា ការជំនុំជម្រះថ្នាក់ជាតិដែលរៀបចំក្រោមច្បាប់កម្ពុជាមិនអាចធ្វើទៅបានទេ ហើយក៏មិនគួរទទួលបាននូវការគាំទ្រផ្នែកហិរញ្ញវត្ថុពីអង្គការសហប្រជាជាតិដែរ។"] ។

[60] របាយការណ៍របស់ក្រុមជំនាញ ត្រង់កថាខណ្ឌ ១០៦ ។

[61] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ២៤ ។

ព្រមព្រៀង អ.វ.ត.ក[62] ។ ស.ម.ត.ដ ជំទាស់ថា "វាជាការរៀបចំឡើងរបស់ប្រទេសកម្ពុជាក៏ដូចជាអង្គការសហប្រជាជាតិដែរ ដើម្បីដកស្រង់បទពិសោធពីតុលាការផ្សេងទៀត"[63] ហេតុដូច្នេះហើយទើបមានការតាក់តែងឡើងនូវបទប្បញ្ញត្តិជាបន្តបន្ទាប់សម្រាប់ធ្វើការកាត់ទោស ។ យោងតាម ស.ម.ត.ដ កិច្ចព្រមព្រៀង អ.វ.ត.ក (ដែលដាក់កម្រិតលើយុត្តាធិការបុគ្គលនោះ) "ត្រូវបានព្រាងឡើងនៅចំពេលដែលអនុសាសន៍នេះត្រូវគេយល់ថា តុលាការ *មិនអចិន្ត្រៃយ៍*ដែលមានស្រាប់កំពុងតែជួបការលំបាកជាមួយនឹងសំណុំរឿងរបស់ខ្លួន"[64] ហើយភាពចន្លោះប្រហោងណាមួយក្នុងបទប្បញ្ញត្តិដែលបានធ្វើឡើងនាពេលនោះ គឺមិនមែនជាបំណងជាក់លាក់ដើម្បី "ផ្តល់និទ្ទណ្ឌភាពទៅឱ្យចារីសម័យខ្មែរក្រហមទាំងអស់ផ្សេងទៀត"[65] ឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ការអះអាងទាំងនេះ មិនមែនជាសម្អតិកម្មទេ ។ ប្រសិនបើនេះជាចេតនារបស់ភាគីនៅពេលនោះមែន នោះនឹងមិនមានអ្វីត្រូវរារាំងពួកគេ មិនឱ្យរួមបញ្ចូលនូវការកំណត់យន្តការបំពេញបន្ថែមទៅក្នុងកិច្ចព្រមព្រៀង ឬបើមិនដូច្នោះទេ ធ្វើការគូសបញ្ជាក់នូវសេចក្តីសង្ឃឹម ឬការរំពឹងទុកនៃដំណើរការដូច្នេះដែរ ។ ការមិនបានបង្ហាញឱ្យដឹងនូវបញ្ហាទាំងនេះ នាំឱ្យគេអាចទាញសេចក្តីសន្និដ្ឋានដ៏សមហេតុផលពីអវត្តមាននៃយន្តការបំពេញបន្ថែមនោះគឺថា ភាគីនៃកិច្ចព្រមព្រៀងរបស់ អ.វ.ត.ក បានព្រាងសេចក្តីដោយចេតនា "នូវទម្រង់ឯកភាពនៃច្បាប់ស្តីពី អ.វ.ត.ក ... ដោយបានដឹងថានឹងមិនមានយុត្តាធិការបំពេញបន្ថែមដោយតុលាការកម្ពុជា"[66] ។

### *iv. សេចក្តីសន្និដ្ឋានរបស់ ស.ច.ស ស្របជាមួយនឹងសេចក្តីថ្លែងការណ៍ និងការអនុវត្តជាបន្តបន្ទាប់នាពេលក្រោយៗមកទៀត*

២៣. ផ្ទុយពីការអះអាងរបស់ ស.ម.ត.ដ[67] ការបកស្រាយយ៉ាងសមហេតុផលរបស់ ស.ច.ស ពីប្រវត្តិ

---

[62] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ២៤-២៥ ។

[63] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ២៥ ។

[64] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ២៥ ។

[65] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ២៥ ។

[66] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារ **D308/3** នៅកថាខណ្ឌ ១៣ ។

[67] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ២៦-២៨ ។

នៃការចរចារបស់ អ.វ.ត.ក ព្រមទាំងការសន្និដ្ឋានអំពីការដែលថាតុលាការសាមញ្ញរបស់កម្ពុជាខ្វះយុត្តាធិការ ត្រូវបានបញ្ជាក់បន្ថែមដោយសេចក្តីថ្លែងការណ៍ និងប្រតិបត្តិការនានារបស់ប្រទេសកម្ពុជានាអំឡុងពេលថ្មីៗនេះ ។ លោកសាស្ត្រាចារ្យ David Scheffer បានថ្លែងយ៉ាងច្បាស់នៅក្នុងអំឡុងនៃកិច្ចចរចាដូច្នេះថា៖

> វាអាស្រ័យទៅលើប្រទេសកម្ពុជា ក្នុងការកំណត់អំពីជោគវាសនារបស់ជនដែលខ្មែរក្រហមថ្នាក់ក្រោម ។ ភារកិច្ចរបស់ អ.វ.ត.ក គឺកាត់ទោសមេដឹកនាំជាន់ខ្ពស់ និងបុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុត ។ ចំណែកជនទាំងឡាយផ្សេងទៀត នឹងត្រូវពឹងផ្អែកទៅលើព្រេងវាសនានៃដំណើរវិវឌ្ឍទៅនៃច្បាប់កម្ពុជា និងសមត្ថភាពប្រព័ន្ធតុលាការជាតិរបស់ខ្លួន[68] ។

២៤. ដំណើរប្រព្រឹត្តទៅបន្តពីនេះ ហាក់ដូចជាការពិចារណាដ៏សំខាន់ក្នុងការកំណត់នូវទស្សនវិស័យ និងចេតនាទូទៅរបស់ប្រទេសកម្ពុជាទាក់ទងនឹងរបៀបដែលច្បាប់កម្ពុជាវិវឌ្ឍទៅមុខ និងសមត្ថភាពរបស់ប្រព័ន្ធតុលាការជាតិ ។

<u>សេចក្តីថ្លែងការណ៍ចំៗ បង្ហាញឱ្យឃើញថា ការកាត់សេចក្តីថ្នាក់ជាតិមិនត្រូវបានព្យាករទេ</u>

២៥. ស.ម.ត.ដ បានអះអាងថា រាជរដ្ឋាភិបាលកម្ពុជាបានធ្វើសេចក្តីថ្លែងការណ៍មួយចំនួន បង្ហាញឱ្យឃើញពី "ការប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព ដែលជារឿងសំខាន់សម្រាប់ដោះស្រាយមរតករបស់ខ្មែរក្រហម"[69] ធ្វើជាភស្តុតាងដើម្បីចោទប្រកាន់ ស.ច.ស ថាបានធ្វើសេចក្តីសន្និដ្ឋានខុស ត្រង់ចំណុចដែលពួកគាត់បានរកឃើញថា តុលាការសាមញ្ញរបស់កម្ពុជាខ្វះយុត្តាធិការដើម្បីកាត់សេចក្តី

---

[68] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ២៣ *យោងទៅ* សេចក្តីថ្លែងការណ៍របស់សាស្ត្រាចារ្យ David Scheffer ធ្វើថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៧ (ភ្ជាប់ក្នុងសារណា ក្នុងឧបសម្ព័ន្ធ A នៅក្នុងសារណារ, ឯកសារលេខ **D308/3/1/9.2**), ត្រង់កថាខណ្ឌ ៨ ។

[69] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ២៦ *យោងទៅ* សេចក្តីថ្លែងការណ៍រួម ធ្វើឡើងរវាងឧបនាយករដ្ឋមន្ត្រីឯកឧត្តម សុខ អាន ជាមួយនឹងលោកស្រី Patricia O'Brien អគ្គលេខាធិការរងនៃ អសប ទទួលបន្ទុកផ្នែកច្បាប់, ទីប្រឹក្សាច្បាប់នៃគម្រោងអង្គការសហប្រជាជាតិជំនួយដល់សាលាក្តីខ្មែរក្រហម ("UNAKRT") ធ្វើនៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១០ (**ភ្ជាប់ជាឯកសារសំអាងលេខ ១៦**) ។

លើឧក្រិដ្ឋកម្មនៅសម័យខ្មែរក្រហម[70] ។ ទោះយ៉ាងណា សេចក្តីថ្លែងការណ៍តែមួយគត់ដែលត្រូវបានដកស្រង់ មិនទាំងជាប់ពាក់ព័ន្ធអ្វីទៅនឹងចំណោទបញ្ហាយុត្តាធិការនៃតុលាការជាតិធម្មតាឡើយ ហើយសេចក្តីថ្លែងការណ៍នេះ គ្រាន់តែសង្កត់ធ្ងន់ពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការគ្នាទៅវិញទៅមក ទាក់ទងនឹងការកាត់ទោសអតីតខ្មែរក្រហមនៅចំពោះមុខ អ.វ.ត.ក តែប៉ុណ្ណោះ[71] ។

២៦. លើសពីនេះ ទោះបីជាផ្តល់នូវដានតូចមួយនៃភស្តុតាងដើម្បីគាំទ្រលើការអះអាងរបស់ ស.ម.ត.ដ ក៏ដោយ ក៏សេចក្តីថ្លែងការណ៍នេះ ត្រូវតែស្ថិតនៅក្នុងបរិបទនៃសេចក្តីថ្លែងការណ៍ក្នុងចំនួនដ៏ច្រើនផ្សេងទៀត ដែលមានទំនោរទៅរកទិដ្ឋភាពផ្ទុយគ្នាស្រឡះពីជំហររបស់ ស.ម.ត.ដ ។ ដោយលើកឡើងពីការបង្រួបបង្រួមជាតិ និងស្ថិរភាពនយោបាយ រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជាក់យ៉ាងច្បាស់ម្តងហើយម្តងទៀតពីការមិនយល់ស្របរបស់ខ្លួនចំពោះការកាត់ទោសទាំងឡាយណា ក្រៅតែពីការកាត់ទោសមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត (ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក)[72] ដោយសំអាងថា ការកាត់ទោសបន្ថែមនៅកម្រិតថ្នាក់ជាតិ ជាការប្រឆាំងជាមួយនឹង

---

[70] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ២៦ *យោងទៅ* សេចក្តីថ្លែងការណ៍រួម ធ្វើឡើងរវាងឧបនាយករដ្ឋមន្ត្រី ឯកឧត្តម សុខ អាន ជាមួយនឹងលោកស្រី Patricia O'Brien អគ្គលេខាធិការរងនៃ អសប ទទួលបន្ទុកផ្នែកច្បាប់, ទីប្រឹក្សាច្បាប់នៃ UNAKRT ធ្វើនៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១០ ។

[71] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ២៦ *យោងទៅ* សេចក្តីថ្លែងការណ៍រួម ធ្វើឡើងរវាងឧបនាយករដ្ឋមន្ត្រី ឯកឧត្តម សុខ អាន ជាមួយនឹងលោកស្រី Patricia O'Brien អគ្គលេខាធិការរងនៃ អសប ទទួលបន្ទុកផ្នែកច្បាប់, ទីប្រឹក្សាច្បាប់នៃ UNAKRT ធ្វើនៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១០ ដោយលើកឡើងថា ["ទាំងរដ្ឋាភិបាល និងអង្គការសហប្រជាជាតិមានការប្តេជ្ញាក្នុងការបញ្ចប់និទ្ទណ្ឌភាព ចំពោះអំពើឃោរឃៅក្នុងរបបខ្មែរក្រហម និងគាំទ្រ ព្រមទាំងគោរពទាំងស្រុងទៅ អ.វ.ត.ក និងដំណើរការនីតិវិធីតុលាការឯករាជ្យ"]។

[72] *សូមមើល*, រាយការណ៍ដោយលោក ជាង សុខា និង James O'Toole, ចំណងជើង៖ 'ហ៊ុន សែន ប្រាប់ទៅ BAN Ki-Moon ៖ ករណី០០២ ជាការជំនុំជម្រះចុងក្រោយនៅ អ.វ.ត.ក,' *អត្ថបទកាសែតកាសែតភ្នំពេញប៉ុស្តិ៍*, ចុះផ្សាយថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១០, [http://www.phnompenhpost.com/national/hun-sen-ban-ki-moon-case-002-last-trial-eccc] (**ភ្ជាប់ជាឯកសារសំអាងលេខ ១៧**) ។ រាយការណ៍ដោយលោក ហេង រស្មី, ចំណងជើង៖ 'ប្រធានគណបក្សប្រជាជនកម្ពុជាអំពាវនាវពីការជំនុំជម្រះជាបន្ទាប់នៅសាលាក្តីខ្មែរក្រហម គឺគ្រប់គ្រាន់សម្រាប់ដំណើរការយុត្តិធម៌,' *វិទ្យុសំឡេងសហរដ្ឋអាមេរិក ព័ត៌មានពីប្រទេសកម្ពុជា*, ចុះផ្សាយថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១១, [https://www.voacambodia.com/a/cpp-chief-calls-next-tribunal-trial-enough-for-justice-125891733/1354698.html] (**ឯកសារសំអាងលេខ ១៨**) ។ រាយការណ៍ដោយលោក សុខ ខេមរា និងលោក ពិន

គោលបំណងសំខាន់ៗនៃយុត្តិធម៌អន្តរកាល ។

២៧. យោងតាមការលើកឡើងរបស់អ្នកស្រី Dinah PoKempner អគ្គប្រឹក្សាធិការនៃអង្គការឃ្លាំមើលសិទ្ធិមនុស្ស ម្ចាស់ជំនួយរបស់ អ.វ.ត.ក និងរដ្ឋបរទេសជាច្រើនផ្សេងទៀត ហាក់ដូចជាទទួលស្គាល់ ឬសូម្បីចែករម្លែកនូវទស្សនៈខាងក្រោមនេះ៖

> ទាំងរដ្ឋាភិបាលកម្ពុជា និងរដ្ឋបរទេសនានា *មានបំណងចង់រក្សាចំនួនជនចុងចោទឱ្យនៅត្រឹមកម្រិតទាប ដើម្បីកាត់បន្ថយការចំណាយ ក៏ដូចជាកាត់បន្ថយនូវភាពតានតឹងផ្នែកនយោបាយ* ។ យើងឃើញមានភាពយ៉ាប់យ៉ឺនខាងនយោបាយ ក្នុងការដាក់ឱ្យមានការទទួលខុសត្រូវលើផ្នែកសំខាន់ណាមួយនៃអតីតខ្មែរក្រហមនាពេលបច្ចុប្បន្ន ចំពោះអំពើឃោរឃៅដែលបានកើតមានឡើងកន្លងមក ឬភាពរកាំចិត្តចំពោះការរំពឹងទុកមិនច្បាស់លាស់អំពីថាតើនឹងមានជនសង្ស័យរូបណាខ្លះ ឋានៈអ្វី[ជាគោលដៅសម្រាប់យកមកវិនិច្ឆ័យទោស] ដែលកាលណាចំនួនជនចុងចោទទាំងនេះទំនងជាអាចឈានដល់មានកម្រិតច្រើនពេក វានឹងគំរាមកំហែងដល់សមាជិកមួយចំនួន ឬដល់អ្នកគាំទ្រគណបក្សប្រជាជនកម្ពុជា ឬបង្កនូវហានិភ័យដល់អតីតខ្មែរក្រហមដែលបានចូលខ្លួនមករួមរស់ជាមួយនឹងរបបគ្រប់គ្រងនេះ ។ *ចំណុចសំខាន់នោះគឺថា ជម្រើសក្នុងការកាត់ទោសដោយ[អង្គជំនុំជម្រះវិសាមញ្ញ] ទំនងជាគ្មានឡើយអំពើនិទណ្ឌភាព វាមិនដូចគ្នានឹងការកាត់ទោសនៅក្នុង*

---

សុវណ្ណ, ចំណងជើង៖ ‘ការបដិសេធការចោទប្រកាន់ពីបទឧក្រិដ្ឋសាហាវយង់ឃ្នងរបស់ខ្មែរក្រហមអំពាវនាវជំរុញឱ្យបិទបញ្ចប់ការចោទប្រកាន់,’ *វិទ្យុសំឡេងសហរដ្ឋអាមេរិក ព័ត៌មានពីប្រទេសកម្ពុជា*, ចុះផ្សាយថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៧ [https://www.voacambodia.com/a/dismissal-of-khmer-rouge-atrocity-charges-sparks-calls-for-end-of-prosecutions/3833154.html] **(ភ្ជាប់ជាឯកសារសំអាងលេខ ១៩)** ។ *សូមមើលផងដែរ, អត្ថបទរបស់* Rupert Skilbeck, ចំណងជើង៖ “ការការពារខ្មែរក្រហម,” *ការពិនិត្យមើលឡើងវិញនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ*, លេខ ៨, ឆ្នាំ ២០០៨ ត្រង់ទំព័រ ៤២៣-៤៤៥ និង ៤៣៤ [“មានជនដែលរាប់ពាន់ នាក់ដែលម្នាក់ៗ អាចនឹងត្រូវបានយកមកផ្តន្ទាទោសក្រោមអាណត្តិដ៏ធំទូលាយមួយ ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលកម្ពុជាជានិច្ចកាលបានបញ្ជាក់យ៉ាងច្បាស់ថាអាណត្តិត្រូវតែមានកម្រិតដើម្បីអនុញ្ញាតឱ្យមានការបង្រួបបង្រួមជាតិកើតមានឡើងដោយសន្តិភាព ស្ថិរភាពនយោបាយ ហើយអង្គភាពជាតិត្រូវបានចាត់ទុកថាជាគោលដៅសំខាន់ដ៏សំខាន់មួយនៃដំណើរការជំនុំជម្រះ”] **(ភ្ជាប់ជាឯកសារសំអាងលេខ ២០)** ។

*កម្រិតថ្នាក់ជាតិទេ*[73] ។

<u>ការអនុវត្តបច្ចុប្បន្នបង្ហាញថាការកាត់ទោសថ្នាក់ជាតិ គឺមិនត្រូវបានព្យាករឡើយ</u>

២៨. ការអនុវត្តជាបន្តបន្ទាប់របស់កម្ពុជានៅក្នុងតុលាការសាមញ្ញរបស់ខ្លួន គឺជាភស្តុតាងបន្ថែមទៀតចំពោះរបកគំហើញទូទៅនេះ ។ ដូចបានកត់សម្គាល់ដោយ ស.ច.ស រួចមកហើយថា គ្មានជនដែលខ្មែរក្រហមណាម្នាក់ត្រូវបានធ្វើការផ្តន្ទាទោសនៅចំពោះមុខតុលាការជាតិនោះទេ[74] ។

*<u>កង្វះក្របខ័ណ្ឌច្បាប់ដើម្បីធ្វើការកាត់ទោសនៅកម្រិតថ្នាក់ជាតិ</u>*

២៩. ដូចបានកត់សម្គាល់ខាងលើ ស.ម.ត.ដ អះអាងថា "មិនថា និងតាមអ្វីដែលមូលដ្ឋានច្បាប់ជាតិសំអាង[នោះទេ] តុលាការកម្ពុជាសាមញ្ញអាចកំណត់ថា ពួកគេអាចដោះស្រាយឧក្រិដ្ឋកម្មទាំងនេះបានឬអត់ គឺជាបញ្ហាមួយសម្រាប់ឱ្យតុលាការទាំងនេះ ដោះស្រាយដោយខ្លួនឯង"[75] គឺជាការអះអាងទទួលយកបាន ។ ទោះជាយ៉ាងណាក៏ដោយ តាមរយៈការពិនិត្យឡើងវិញនូវភាពអសកម្មនៃនីតិប្បញ្ញត្តិ និងដំណើរការចោទប្រកាន់របស់រដ្ឋាភិបាលទាក់ទងនឹងការកាត់ទោសបន្ថែម បង្ហាញបានថា កម្ពុជាបានកំណត់លើបញ្ហានេះរួចហើយ និងបានសន្មតថាការកាត់ទោសបន្ថែមទៀតនៃឧក្រិដ្ឋកម្មទាំងនេះ នឹងមិនមានប្រសិទ្ធភាពទេ ហើយអាចនាំឱ្យមានការបំពាននូវសិទ្ធិជាមូលដ្ឋាននៃការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ។

៣០. មាត្រា ៦១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា "អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា និងអាជ្ញាយុកាលនៃទោសចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្តនៅមុនក្រមនេះចូលជាធរមាន ត្រូវអនុវត្ត

---

[73] អត្ថបទនិពន្ធដោយអ្នកស្រី Dinah PoKempner, អគ្គប្រឹក្សាធិការឱ្យអង្គការឃ្លាំមើលសិទ្ធិមនុស្ស ក្រោមចំណងជើងថា៖ 'សាលាក្តីខ្មែរក្រហម: ការរិះគន់ និងកង្វល់នានា,' នៅក្នុងព្រឹត្តប័ត្ររបស់ *Justice Initiatives*, របាយការណ៍របស់អង្គការ Open Society Justice Initiative, និទាឃរដូវ ឆ្នាំ២០០៦ ត្រង់ទំព័រលេខ ៣៩ (សង្កត់ន័យបន្ថែមត្រង់អក្សរទ្រេត) (**ភ្ជាប់ជាឯកសារសំអាងលេខ ២១**) ។

[74] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះនៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ២៤ ។

[75] សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ៣១ ។

តាមបទប្បញ្ញត្តិនៃច្បាប់ចាស់”[76] ។ ច្បាប់ចាស់ដែលអាចអនុវត្តបានក្នុងអំឡុងសម័យខ្មែរក្រហម គឺជាក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលមានរយៈពេលកំណត់ត្រឹមដប់(១០)ឆ្នាំសម្រាប់បទឧក្រិដ្ឋ[77] ។ ក្រោយការផុតកំណត់អាជ្ញាយុកាលពាក់ព័ន្ធលើបទល្មើសជាក់លាក់ណាមួយហើយនោះ “បណ្តឹងអាជ្ញាត្រូវផុតរលត់ ហើយការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិនអាចចាប់ផ្តើមបានទៀតទេ [និង] ត្រូវតែបញ្ឈប់”[78] ។ នៅក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកថា ការស៊ើបអង្កេត និងការចោទប្រកាន់លើបទល្មើសព្រហ្មទណ្ឌត្រូវបានផ្អាកនៅចន្លោះឆ្នាំ១៩៧៥ និង១៩៧៩ ដូច្នេះវារារាំងនូវចិរវេលាកំណត់រយៈពេល១០ឆ្នាំ នៃអាជ្ញាយុកាលចំពោះបទឧក្រិដ្ឋពីការចាប់ផ្តើមរវាងកាលបរិច្ឆេទក្នុងពេលនោះ[79] ។ ថ្វីបើចៅក្រមអង្គជំនុំជម្រះសាលាដំបូងមានគោលជំហរខុសគ្នាចំពោះករណីដែលថាតើការផ្អាកនេះនៅតែបន្តរហូតដល់ឆ្នាំ១៩៧៩ ឬយ៉ាងណា[80] កាលបរិច្ឆេទចុងក្រោយបំផុតដែលអាជ្ញាយុកាលត្រូវបានគេចាត់ទុកថាបានចាប់ផ្តើមនៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ

---

76 ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៦១០ (**ភ្ជាប់ជាឯកសារសំអាងលេខ ២២**) ។

77 ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ មាត្រា ១០៩ (**ភ្ជាប់ជាឯកសារសំអាងលេខ ២៣**) ។ *សូមមើល, រឿងក្តីរបស់ កាំង ហ្គេកអ៊ាវ ហៅ “ឌុច” សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អជសដ*, សេចក្តីសម្រេចស្តីពី អញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិដែលលើកឡើងដោយមេធាវីការពារក្តី ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, ឯកសារ **E187**, ត្រង់ជើងទំព័រលេខ ១៣ ។

78 ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា ៧ ។

79 *រឿងក្តីរបស់ កាំង ហ្គេកអ៊ាវ ហៅ “ឌុច” សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អជសដ*, សេចក្តីសម្រេចស្តីពី អញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិដែលលើកឡើងដោយមេធាវីការពារក្តី ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, ឯកសារ **E187**, ត្រង់កថាខណ្ឌ ១៤ ។

80 *រឿងក្តីរបស់ កាំង ហ្គេកអ៊ាវ ហៅ “ឌុច” សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អជសដ*, សេចក្តីសម្រេចស្តីពី អញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិដែលលើកឡើងដោយមេធាវីការពារក្តី ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, ឯកសារ **E187**, ត្រង់កថាខណ្ឌ ២៥ [ចៅក្រមជាតិសន្និដ្ឋានថា៖ “ចិរវេលានៃអាជ្ញាយុកាលពាក់ព័ន្ធទៅនឹងបទល្មើសជាតិដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ចាប់ផ្តើមរាប់ពីថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣”] ។ ត្រង់កថាខណ្ឌ ២៧ [ចៅក្រមអន្តរជាតិសន្និដ្ឋានដូច្នេះវិញថា ពួកគាត់ “មិនអាចសន្និដ្ឋានបានថា ចិរវេលានៃអាជ្ញាយុកាលដែលអាចអនុវត្ត ត្រូវបានព្យួរនៅចន្លោះឆ្នាំ ១៩៧៩ ដល់ឆ្នាំ១៩៩៣”] ។

១៩៩៣[81] ។ ដូចនេះ អាជ្ញាយុកាលលើឧក្រិដ្ឋកម្មថ្នាក់ជាតិបច្ចុប្បន្ននេះ បានកន្លងផុតហើយ។

៣១. ក្រៅពីបរិបទនៃ អ.វ.ត.ក ចិរវេលាកំណត់មិនត្រូវបានពន្យារឡើយ: មាត្រាទី៣ (ថ្មី)នៃច្បាប់ អ.វ.ត.ក គឺមិនអាចយកទៅអនុវត្តបាននៅចំពោះមុខតុលាការសាមញ្ញរបស់កម្ពុជាទេ ។ ការពន្យារអាជ្ញាយុកាលដែលមានចែងនៅក្នុងបទប្បញ្ញត្តិនេះ គឺតម្រូវឱ្យអនុវត្តទាំងស្រុងតែនៅក្នុងដែន "សមត្ថកិច្ចនៃអង្គជំនុំជម្រះវិសាមញ្ញ" ប៉ុណ្ណោះ[82] និងមិនអនុញ្ញាតឱ្យមានយុត្តាធិការបន្ថែមទៀតក្នុងតុលាការសាមញ្ញរបស់កម្ពុជាឡើយ ។ ហេតុដូច្នេះហើយ ដំណើរការនីតិវិធីនៅពេលបច្ចុប្បន្ននេះ ពុំអាចអនុវត្តបានទេនៅតុលាការសាមញ្ញរបស់កម្ពុជា ចំពោះបទល្មើសដែលបានចោទប្រកាន់ក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ សម្រាប់ការប្រព្រឹត្តនៅរវាងឆ្នាំ១៩៧៥ និង ១៩៧៩ ។ កង្វះនៃសកម្មភាពនីតិប្បញ្ញត្តិ ឬនីតិប្រតិបត្តិរបស់កម្ពុជាចំពោះបញ្ហាទាំងនេះ ឆ្លុះបញ្ចាំងនូវទស្សនៈរបស់ចៅក្រមអន្តរជាតិពីររូបនៃអង្គជំនុំជម្រះសាលាដំបូង ដែលបានចាត់ទុកថា ("តាមសញ្ញាណនៃភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ គោលការណ៍សុវត្ថិភាពគតិយុត្តិ និងគោលការណ៍ជំនុំជម្រះក្តីដោយយុត្តិធម៌" គាំទ្រលើសេចក្តីសន្និដ្ឋានដែលថា ការកែប្រែច្បាប់ឡើងវិញក្រោយព្រឹត្តិការណ៍ល្មើសបានកើតឡើងរួចហើយ ដើម្បីស្វះស្វែងឱ្យមានការកាត់ទោសព្រហ្មទណ្ឌ គឺមិនអាចអនុញ្ញាតឱ្យអនុវត្តបានទេ)[83] ព្រមទាំងគាំទ្រផងដែរលើករណីយុត្តិសាស្ត្រនៃតុលាការសិទ្ធិមនុស្សអឺរ៉ុប

---

[81] *រឿងក្តីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អជសដ,* សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិដែលលើកឡើងដោយមេធាវីការពារក្តី ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១០, ឯកសារ **E187**, ត្រង់កថាខណ្ឌ ២៥ ។

[82] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ សម្រាប់ការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ត្រង់មាត្រា ៣ ថ្មី ។

[83] *រឿងក្តីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច", សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អជសដ,* សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិដែលលើកឡើងដោយមេធាវីការពារក្តី ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១០, ឯកសារ **E187**, ត្រង់កថាខណ្ឌ ៥០ ។ *សូមមើលផងដែរ, រឿងក្តីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អជតក,* សាលដីកានៃសំណុំរឿង០០១, ឯកសារ **F28** ត្រង់កថាខណ្ឌ ៩៦ [ដោយកត់សម្គាល់ពីសញ្ញាណនូវទម្រង់នៃភាពអាចយល់ដឹងជាមុនបាន គឺជាផ្នែកមួយនៃគោលការណ៍នីត្យានុកូលភាពនៃច្បាប់] ។ *រឿងក្តីរបស់ នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ត.ក, សាលដីកាអង្គជំនុំជម្រះតុលាការកំពូល* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦, ឯកសារ **F36**, ត្រង់កថាខណ្ឌ ៧៦០

(ECtHR) (ការព្យាយាមទាំងឡាយណា ធ្វើឡើងដើម្បីឱ្យមានការចោទប្រកាន់ឡើងវិញ បន្ទាប់ពីអាជ្ញាយុកាលបទល្មើសបានផុតរលត់ទៅហើយនោះ គឺជាទង្វើផ្ទុយទៅនឹងគោលការណ៍នីត្យានុកូលភាព)[84] ។

៣២. ទោះបីជាយ៉ាងណា សូម្បីតែសន្មតថា ស្រេចតែលើប្រទេសកម្ពុជាខ្លួនឯងក្នុងការពង្រីកការរីតត្បិតយុត្តាធិការពេលវេលាក្តី ក៏ការពិតដែលនៅតែមានគឺថា រាជរដ្ឋាភិបាលកម្ពុជាបានជ្រើសយកចិរវេលាកំណត់រយៈពេល១០ឆ្នាំសម្រាប់ការអនុវត្តនៅតុលាការសាមញ្ញរបស់ខ្លួនដែរ ។ និយាយម្យ៉ាងទៀត ទង្វើនិងការប្រព្រឹត្តរបស់ប្រទេសកម្ពុជា បញ្ជាក់នូវការគាំទ្របន្ថែមទៀតចំពោះទស្សនៈកំណត់ដោយ ស.ច.ស ចំពោះចេតនាដាក់កម្រិតយុត្តាធិការលើតុលាការសាមញ្ញរបស់ខ្លួន ។

*ឧក្រិដ្ឋកម្មអន្តរជាតិ*

៣៣. ស.ម.ត.ដ តវ៉ាថា "តុលាការកម្ពុជាអាចសម្រេចថា រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជាអនុញ្ញាតឱ្យ ឬក៏សឹងតែតម្រូវឱ្យមានការប្រើប្រាស់ដោយផ្ទាល់នូវបទល្មើសដែលត្រូវបានទទួលស្គាល់ក្រោមច្បាប់ព្រហ្មទណ្ឌទំនៀមទំលាប់អន្តរជាតិ សម្រាប់ឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម"[85] ។ ទោះជាយ៉ាងណាក្តី លទ្ធភាពនេះនៅតែជាទ្រឹស្តីទាំងស្រុង ។ មានឧបសគ្គជាច្រើនអាចប្រឈមទល់នឹងការជ្រើសយកជំហានដូច្នេះ ។

៣៤. មាត្រា៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ចែងអំពីគោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់ចែង (nullum crimen sine lege)* និងគោលការណ៍*គ្មានការដាក់ទណ្ឌកម្ម បើគ្មានចែងក្នុងបទប្បញ្ញត្តិ*

---

[ដោយកត់សម្គាល់ពីសញ្ញាណនូវទម្រង់នៃភាពអាចយល់ដឹងជាមុនបាន គឺជាផ្នែកមួយនៃគោលការណ៍នីត្យានុកូលភាពនៃច្បាប់] ។ *រឿងក្តីរបស់ នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ, សេចក្តីសម្រេចលើសំណើសុំដោះលែងបន្ទាន់របស់ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ* ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារ **E50**, ត្រង់កថាខណ្ឌ ២៩ [ដោយកត់សម្គាល់ថា គោលការណ៍នីត្យានុកូលភាពនៃច្បាប់ គឺជា "មូលដ្ឋានគ្រឹះក្នុងការធានានូវការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌"] ។

84 រឿងក្តី *Kononov ទល់នឹង Latvia* (លេខៈ 36376/04), សាលក្រមតុលាការសិទ្ធិមនុស្សអឺរ៉ុប (ECtHR), ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៨ ត្រង់កថាខណ្ឌ ១៤៤-១៤៦ (**ភ្ជាប់ជាឯកសារសំអាងលេខ ២៤**) ។

85 សារណារបស់ ស.ម.ត.ដ ត្រង់កថាខណ្ឌ ៣១ ។

ច្បាប់ *(nulla poena sine lege)*[86] ។ នៅក្នុងបរិបទនៃការអនុវត្តក្នុងប្រទេសចំពោះឧក្រិដ្ឋកម្មអន្តរជាតិ គោលការណ៍នីត្យានុកូលភាពតម្រូវឱ្យមាន "ការអនុម័តច្បាប់នានាស្តីពីការដាក់ទណ្ឌកម្មមុនពេលយកទៅអនុវត្ត"[87] ។ ស្របតាមបទដ្ឋានអន្តរជាតិនានា អង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក បានកត់សម្គាល់ថា សុពលភាពនៃយុត្តាធិការរបស់តុលាការលើឧក្រិដ្ឋកម្មណាមួយ គឺវាអាស្រ័យលើវត្តមាននៃបទល្មើសនៅក្នុងក្របខ័ណ្ឌច្បាប់ដែលគ្រប់គ្រងលើតុលាការនោះ[88] ។ អ.ប.ជ ក៏បានថ្លែងបញ្ជាក់ផងដែរថា ការអនុលោមទៅតាមគោលការណ៍នីត្យានុកូលភាព គឺតម្រូវឱ្យមាន*នៅក្នុងនោះ* អត្ថិភាពនៃច្បាប់ដែលផ្តល់យុត្តាធិការលើបទល្មើសដែលជាបញ្ហាចោទ[89] ។ ប្រការនេះ វាដូចគ្នាផងដែរទៅនឹងប្បញ្ញត្តិច្បាប់ផ្សេងៗសម្រាប់យកមកធ្វើការកាត់សេចក្តី ។

៣៥. ឧទាហរណ៍ ដូចបានទទួលស្គាល់ដោយ ស.ច.ស ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលអាចអនុវត្តបាន

---

[86] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៩ ត្រង់មាត្រា ៣ (**ភ្ជាប់ជាឯកសារសំអាងលេខ ២៥**) ។

[87] រៀបរៀងដោយ M. Cherif Bassiouni, *សេចក្តីណែនាំស្តីពីច្បាប់ព្រហ្មទណ្ឌអន្តរជាតិ*, (បោះពុម្ពលើកទី២ ដោយ Martinus Nijhoff, ឆ្នាំ២០១៣) ត្រង់ទំព័រ៤៧៥ ["ប្រសិនបើបទល្មើសអន្តរជាតិគឺ ... អនុវត្តដោយផ្ទាល់នៅ ក្នុងនីតិវិធីច្បាប់ជាតិដោយកាលណាគ្មានអន្តរច្បាប់នៃច្បាប់ព្រហ្មទណ្ឌក្នុងប្រទេស បញ្ហាចោទនឹងកើតមានឡើងចំពោះថាតើទោសទណ្ឌអ្វីដែលត្រូវយកមកអនុវត្ត ។ អ្វីដែលធ្វើអោយមានបញ្ហាស្មុគស្មាញនោះគឺថា គោលការណ៍នៃនីត្យានុកូលភាពរួមបញ្ចូលទាំងតម្រូវការមួយចំនួន នៃការអនុម័ត លើទណ្ឌកម្មមុនពេលអនុវត្តគោលការណ៍នេះ ។ នេះគឺជាគោលការណ៍*គ្មានការដាក់ទណ្ឌកម្ម បើគ្មានចែងក្នុងបទប្បញ្ញត្តិ ច្បាប់* (nulla poena sine lege)"] ។

[88] *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច" សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អជតក*, សាលដីកានៃសំណុំរឿង ០០១, ឯកសារ **F28** ត្រង់កថាខណ្ឌ ៩៨ *ដកស្រង់ រឿងក្តី* Prosecutor ទល់នឹង *Milan Milutinović និងអ្នកដទៃផ្សេងទៀត*, សំណុំរឿងលេខ (IT-99-37-AR72), សាលដីកាតុលាការកំពូល, សេចក្តីសម្រេចលើញត្តិ របស់លោក Dragoljub Ojdanić ដែលតវ៉ាលើបញ្ហាសហកម្មឧក្រិដ្ឋកម្មរួម, ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៣, កថាខណ្ឌ ២១ (**ភ្ជាប់ជាឯកសារសំអាងលេខ ២៦**) ។ *រឿងក្តី Prosecutor ទល់នឹង Vidoje Blagojević និង Dragan Jokić*, សំណុំរឿងលេខ (IT-02-60-T), សាលក្រមសាលាដំបូង ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥, នៅកថាខណ្ឌ ៦៩៥ ត្រង់ជើងទំព័រ ២១៤៥ (**ភ្ជាប់ជាឯកសារសំអាងលេខ ២៧**) ។ *រឿងក្តី Prosecutor ទល់នឹង Milomir Stakić*, សំណុំរឿងលេខ (IT-97-24-T), សាលក្រមសាលាដំបូង ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៣, នៅកថាខណ្ឌ ៤៣១ (**ភ្ជាប់ជាឯកសារសំអាងលេខ ២៨**) ។

[89] *រឿងក្តីរបស់ នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស (អបជ ៧៥), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១, ឯកសារ **D427/1/30**, ត្រង់កថាខណ្ឌ ២១២ ។

នៅក្នុងសម័យខ្មែរក្រហម មិនបានសំដៅទៅលើបទប្បញ្ញត្តិណាមួយបញ្ជាក់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[90] ឬក៏មានការចែងច្បាប់ពាក់ព័ន្ធណាមួយពីការផ្តន្ទាទោសចំពោះការប្រព្រឹត្តបទឧក្រិដ្ឋបែបនេះឡើយ[91] ។ រហូតមកដល់ពេលនេះ កម្ពុជាបានជ្រើសយកជម្រើសមិនស្វះស្វែងឱ្យមានការកែប្រែច្បាប់នេះ ឬក៏ធ្វើការកាត់ទោសនៅថ្នាក់ជាតិ លើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តទៅនៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ នោះទេ ។ នៅរវាងពេលវេលាចន្លោះទាំងនេះ កម្ពុជាប្រហែលជាអាចត្រូវបានធ្វើការសម្រេចចាត់វិធានការទាំងនេះ ឬជ្រើសយកជំហានចាំបាច់ផ្សេងៗទៀត ដែលអាចជាហានិភ័យរំលោភលើធាតុផ្សំស្នូលនៃគោលការណ៍នីត្យានុកូលភាព[92] ។

៣៦. សរុបមក សារណារបស់ ស.ម.ត.ដ មិនត្រឹមតែបកស្រាយខុសទៅលើកម្មវត្ថុ គោលបំណង និងប្រសិទ្ធិភាពនៃការវិភាគរបស់ ស.ច.ស ពីជំហរ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែអ្វីដែលពួកគេបានផ្តល់ គឺគាំទ្រតិចតួចណាស់សម្រាប់ការតវ៉ារបស់ខ្លួន ដើម្បីឱ្យមានការទទួលយកទៅពិចារណា ដែលការនេះ ធ្វើឱ្យប៉ះពាល់ដល់សំអាងហេតុនៃការយល់ឃើញរបស់ ស.ច.ស ក្នុងការសន្និដ្ឋានថាប្រទេសកម្ពុជាបានអនុវត្តសិទ្ធិអធិបតេយ្យភាពរបស់ខ្លួន ។ ដូច្នោះហើយ សំណើរបស់ ស.ម.ត.ដ សុំឱ្យធ្វើការកែប្រែនូវការរកឃើញក្នុងដីកាដំណោះស្រាយ នៅតែមិនអាចទទួលយកបាន និងធ្វើឡើងដោយគ្មានមូលដ្ឋាន ។ ដូចបានអះអាងពីខាងដើមថា អ.ប.ជ មិនមែនជាវេទិកាសមស្របដើម្បីធ្វើការកែប្រែតាមដែល ស.ម.ត.ដ បានស្នើសុំនោះទេ ។

## IV. សំណើ

---

[90] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ២១ ។

[91] *សូមមើល*, ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារ **D308/3** កថាខណ្ឌ ២១ ។

[92] អត្ថបទរៀបរៀងឡើងដោយ M. Cherif Bassiouni, *សេចក្តីណែនាំអំពីច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* (បោះពុម្ពលើកទីពីរដោយ Martinus Nijhoff ឆ្នាំ ២០១៣) ត្រង់ទំព័រ ២៤៦-២៤៧ ["មិនថាប្រភពអ្វីក៏ដោយ វិធានច្បាប់ហាមឃាត់ដែលបានបង្កើតឡើងនៅក្នុង [ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ] ត្រូវតែបំពេញនូវតម្រូវការនៃគោលការណ៍នីត្យានុកូលភាព ។ គោលការណ៍ទាំងនេះតម្រូវថា គ្មានបទឧក្រិដ្ឋ បើគ្មានច្បាប់ចែង (*គ្មានបទល្មើស បើគ្មានច្បាប់ចែង nullum crimen sine lege*) គ្មានការផ្តន្ទាទោសដោយគ្មានច្បាប់ (*គ្មានការដាក់ទណ្ឌកម្ម បើគ្មានចែងក្នុងបទប្បញ្ញត្តិច្បាប់ nulla poena sine lege*) និងគ្មានការអនុវត្តច្បាប់ដែលកើតក្រោយបទល្មើសឡើយ *ex post facto*"] ។

ចំពោះហេតុផលដែលបានលើកឡើងខាងលើ ក្រុមការពារក្តីសូមស្នើដោយគោរពដល់ អ.ប.ជ មេត្តាសម្រេចមិនទទួលយកនូវសារណារបស់ ស.ម.ត.ដ ឬជម្រើសផ្សេងពីនេះ សូមមេត្តាសម្រេចថា ការបកស្រាយរបស់ ស.ចៃ.ស អំពីជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា គឺជាការបកស្រាយសមហេតុផល ៕

សូមមេត្តាទទួលយកសារណានេះដោយគោរព ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជាថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៧

សហមេធាវីការពារក្តីអ្នកស្រី អ៊ឹម ចែម

| | |
|---|---|
| [ហត្ថលេខា] | [ហត្ថលេខា] |
| ប៊ិត ស៊ាងលីម | Wayne JORDASH, QC |